ឆ្នាំគ្រួសារ ២០១៧-២០២០

# អ្នកនាំសារ
THE MESSENGER

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១១ | សម្រាប់ខែ សីហា ឆ្នាំ ២០១៩ | តម្លៃលក់ ១០០០រៀល | លេខ #១២២

## តើស្ថាប័នណាដឹងថា ការដ្ឋានសំណង់ទាំងអស់នៅកម្ពុជា ត្រូវការខ្សាច់និងឥដ្ឋប៉ុន្មានទេ?

> ទំព័រ ១០-១១





## វិចារណកថា

# «ការស្រឡាញ់បរិស្ថាន ក៏ដូចជាស្រឡាញ់ព្រះជាម្ចាស់ និងបងប្អូនដែរ»

*រូបភាព៖ Freepik*

បងប្អូនជាទីស្រឡាញ់ ពេលចាប់ផ្តើមរដូវភ្លៀង យើងក៏បានពត៌មានភ្លាម អំពីជំងឺគ្រុនឈាម។ មានកុមាររាប់រយនាក់ ចូលមន្ទីរពេទ្យជាបន្តបន្ទាប់ មានទាំងស្រាល និងធ្ងន់ធ្ងរ។ ហើយក៏មានអ្នកជំងឺខ្លះ ស្លាប់បាត់បង់ជីវិតផងដែរ។ តែមួយចំណែកក៏គិតថា តើហេតុអ្វី យើងមិនជួយគ្នាការពារ ហេតុការណ៍នៃកំណើត «មូសខ្លា» ដែលជាសត្វល្អិតចម្លង របស់ជំងឺនេះ? យើងអាចកំចាត់មូស ដោយមិនបង្កើតកន្លែងដក់ទឹកភ្លៀង ដែលនាំឲ្យមូសអាចបង្កកំណើតបាន ក៏ដូចជា សំរាមថង់ផ្លាស្ទិក កង់កៅស៊ូចាស់ៗ ឬរបស់បាក់បែកដែលអាចដក់ទឹកបាន ហើយបោះចោលឲ្យហាលភ្លៀង។ ចំណុចទាំងនេះ យើងត្រូវជួយគ្នា មិនគ្រាន់តែជាតួនាទីរបស់អាជ្ញាធរទេ។

រឿងនេះ នាំឲ្យយើងគិតដល់ «បរិស្ថាន» ជុំវិញយើង។ សម្រាប់គំនិតខាងគ្រីស្តសាសនា ព្រះជាម្ចាស់ឲ្យមនុស្សគ្រប់គ្រងសព្វសារពើ ដែលព្រះជាម្ចាស់បង្កើត( កណ ១,៣០ ) ប៉ុន្តែសព្វថ្ងៃនេះ មនុស្សយើងធ្វេសប្រហែសយ៉ាងខ្លាំង មិនយកចិត្តទុកដាក់គ្រប់គ្រងវាឲ្យបានល្អនោះទេ។ យើងអាចឃើញលទ្ធផលប្រចាំថ្ងៃ គឺ «ការបង្កើតសំរាម» ជាពិសេស សំរាមប្រភេទប្រើម្តងហើយបោះចោល ព្រោះវាបំពុលបរិស្ថានយ៉ាងច្រើន។ វាមិនងាយរលួយទេ ទោះបីជារលួយ វាក៏ក្លាយទៅជាកម្ទេចផ្លាស្ទិកតូចៗ ហៅ Micro-plastic ដែលក្រោយមក សត្វត្រី ឬសត្វដែលស៊ីវាក៏ពុលងាប់។ បើមិនដូច្នោះទេ មីក្រូផ្លាស្ទិកទាំងនោះ ក៏អាចចូលក្នុងសាច់សត្វទាំងនោះ ហើយអាចត្រឡប់មកយើងវិញ។ មានន័យថា យើងកំពុងសម្លាប់ខ្លួនឯងបន្តិចម្តងៗដែរ។

ការបំផ្លាញដើមឈើ ដែលជាជំនួយដ៏សំខាន់របស់មនុស្ស ដែលជួយសំអាត និងការពារការប្រែប្រួលអាកាសធាតុ។ បញ្ហាគឺមនុស្សខ្វះការទទួលខុសត្រូវ កាប់ហើយមិនដាំដើមឈើជំនួស ធ្វើឲ្យគម្របព្រៃឈើសឹករិចរឹល។ អង្គការសហប្រជាជាតិ មានពាក្យស្លោកឆ្នាំ ២០១៩ នេះថា «ឈប់បំពុលខ្យល់អាកាស» ( Beat Air Pollution ) ជាពិសេសប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានការដុតព្រៃជារៀងរាល់ឆ្នាំ។ សម្តេចប៉ាបហ្វ្រង់ស៊ីស្កូមានប្រសាសន៍ថា នេះមកពីមូលហេតុពិភាពក្រីក្ររបស់ប្រជាជន ដែលរាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់។

គ្រីស្តសាសនាបង្រៀនឲ្យស្រឡាញ់បងប្អូន ដូចស្រឡាញ់ខ្លួនឯង ( មក១២,៣១ ) សន្តឬមនុស្សដែលមានគុណធម៌កំរិតខ្ពស់ មានឈ្មោះថា ហ្វ្រង់ស៊ីស្កូ នៅក្រុងអាស្ស៊ីស៊ី ជាគំរូដ៏ល្អ សម្រាប់មនុស្សគ្រប់ជំនាន់។ លោកពិសាបាយតិចរស់នៅបែបសាមញ្ញបំផុត និងចាត់ទុកបរិស្ថាននិងធម្មជាតិទាំងអស់ដូចជាបងប្អូន។ លោកអរព្រះគុណព្រះជាម្ចាស់ជានិច្ច ដែលប្រទានពិភពលោកដ៏ប្រណិតនេះឲ្យមនុស្ស ដូច្នេះគ្រីស្តបរិស័ទមានគំរូហើយ ចំពោះការរស់នៅដោយជិតស្និទ្ធនឹងបរិស្ថាន។ ការប្រើប្រាស់គ្រប់ធម្មជាតិដើម្បីភាពសុខស្រួលរបស់មនុស្ស ចំពោះគ្រីស្តបរិស័ទគឺ «បាប» ព្រោះយើងខ្វះសេចក្តីស្រឡាញ់។ ការបំពុលបរិស្ថាន គឺការប្រព្រឹត្តបាប ចំពោះបងប្អូនជនរួមស្លាក់អាស្រ័យក្នុងពិភពលោក។ ការសម្លាប់សត្វព្រៃ ការបង្ហូចទឹកទន្លេឬសមុទ្រ ដោយសារសំរាម ការចាក់កាកសំណល់ពីរោងចក្រ ពីឡាន ពីផ្ទះដោយខ្វះការយកចិត្តទុកដាក់ ឬខ្វះការព្យាយាមទទួលខុសត្រូវ គឺជាអំពើបាប ដោយសារ «ការខានបំពេញកិច្ចការរបស់ខ្ញុំ» ដូចគ្រីស្តបរិស័ទតែងតែសូត្រត់មាត់ក្នុងធម៌សារភាព។

តើយើងអាចធ្វើអ្វី ដើម្បីជួយបរិស្ថានអំពីរឿងនេះ? យើងអាចធ្វើបាន ៣ យ៉ាងគឺ៖

១-បន្ថយការប្រើប្រាស់ ( Reduce )៖ ធ្វើយ៉ាងម៉េច យើងត្រូវបង្កើតសំរាមឲ្យតិចបំផុត បន្ថយការហូបយ៉ាងខ្ជីខ្ជា ជាពិសេស សាច់របស់សត្វធំឬសត្វជើងបួន ព្រោះការចិញ្ចឹមពួកវា បង្កើតឧស្ម័នហ្គាសដែលធ្វើឲ្យពិភពលោកយើងឡើងកំដៅ។ យើងប្រើតែអ្វីដែលចាំបាច់ និងចេះគ្រប់គ្រាន់បានហើយ។ ពេលយើងមានហើយ កុំលោភលន់យកថែមទៀតរហូតដល់យើងបោះចោល ជាពិសេស ពេលយើងចូលហាងរបៀបបុបហ្វេ ( Buffet )។

២-ការប្រើប្រាស់ឡើងវិញ ( Reuse )៖ គឺការប្រើប្រាស់របស់របរដែលយើងគិតថា អាចកែច្នៃ ប្រើប្រាស់ជាអត្ថប្រយោជន៍ផ្សេង ឬប្រសិនយើងអាចជួសជុលបាន ក៏ជាការពន្យាអាយុកាលប្រើប្រាស់របស់នោះកាន់តែបានយូរ។ នេះជួយបន្ថយសំរាមផង ជួយពិភពលោកយើងផង ដូចជា ខោអាវ របស់អេឡិចត្រូនិកផលិតពីផ្លាស្ទិក ជាដើម។

៣-ការធ្វើថ្មីឡើងវិញ ( Recycle )៖ ក្នុងចំណោមពួកយើងខ្លះអាចជាអ្នកធ្វើឡើងវិញ ប៉ុន្តែភាគច្រើន យើងអាចធ្វើបាន គឺជាអ្នកជួយចែកញែកប្រភេទសំរាម។ មុនយើងបោះសំរាម យើងត្រូវរិះគិត ព្រោះមិនមែនទាំងអស់គឺសំរាមទេ។ ប៉ុន្តែវាគឺជារបស់ដែលមានតម្លៃ ដូចជា ក្រដាស និងដបផ្លាស្ទិកអាចយកទៅធ្វើឡើងវិញបាន។ កាកសំណល់ យើងទុកជាជីបានឬរបស់ចាស់ក៏អាចជួសជុលហើយចែកចាយឲ្យអ្នកផ្សេងបានដែរ។

សូមបងប្អូនជួយគ្នា ហើយជឿជាក់ថា យើងធ្វើបាន ហើយចាប់ផ្តើមពីខ្លួនឯងមុន ដើម្បីពិភពលោករបស់យើងក្លាយទៅជាកន្លែងដែលយើងអាចរស់នៅដោយផាសុកភាព និងជាមរតកបន្តឲ្យបុត្រធីតារបស់យើងនៅពេលអនាគត។ ចំពោះបងប្អូនដែលជាគ្រីស្តបរិស័ទ នេះគឺជាឱកាស ដើម្បីបង្ហាញសេចក្តីស្រឡាញ់តាមព្រះបន្ទូលយ៉ាងពិតប្រាកដ៕

*ដោយលោកបូជាចារ្យ រឿង ឆ័ត្រសិរី*
*តំណាងលោកអភិបាលសម្រាប់*
*ការិយាល័យពត៌មានកាតូលិក*

Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខ៖ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

# របាំព្រះរាជទ្រព្យ ជារបាំសម្ដែងដោយកម្រ

**របាំព្រះរាជទ្រព្យ ជាកេរ្ដិ៍ដំណែលប្រវត្តិសាស្ត្រដ៏យូរលង់មួយរបស់កម្ពុជា។ ក្បាច់បាតនៃរបាំ ត្រូវបានបំបែកជារបាំផ្សេង ៗទៀត ដូចជាល្ខោនខោល របាំទេពមនោរម្យ ជាដើម។ ប្រជាជនខ្មែរភាគច្រើនមិនសូវបានទស្សនារបាំព្រះរាជទ្រព្យនេះទេ ហើយ អ្នកខ្លះក៏ប្រហែលមិនធ្លាប់បានស្គាល់ទៀតផង ដោយសាររបាំនេះ មិនត្រូវបានសម្ដែងជាសាធារណៈញឹកញាប់នោះទេ។**

*ដោយៈ ផល សុផានិត*

«សំឡេងអឺៗអើយមោះមុត ថាអើយ មោះមុត គ្រប់គ្នា» នេះជាពំនោលមួយក្នុងការច្រៀងចម្រៀងក្នុងរបាំព្រះរាជទ្រព្យ ដែលសម្ដែងជូនទស្សនិកជនយ៉ាងកម្របំផុត កាលពីពេលថ្មីៗនេះ នៅក្នុងមហោស្រពចតុមុខ ក្រោមប្រធានបទ ប្រវត្តិមួយសតវត្សនៃរបាំព្រះរាជទ្រព្យខ្មែរ ដែលរៀបចំដោយសម្ដេចព្រះរាជបុត្រី ព្រះរាម នរោត្តម បុប្ផាទេវី។



ក្រុមសម្ដែងរបាំព្រះរាជទ្រព្យ ដែលសម្ដែងជូនទស្សនិកជនទស្សនា។ *រូបភាពៈ សហការី*

បុព្វីរសិល្បការិនីរបាំព្រះរាជទ្រព្យ សម្ដេចព្រះរាជបុត្រី ព្រះរាម នរោត្តម បុប្ផាទេវី មានព្រះសវនីយថា កាលពីបុរាណកាល របាំនេះត្រូវបានព្រះមហាក្សត្រ យកទៅសម្ដែងថ្វាយព្រះសិរៈ វត្ថុសក្ដិសិទ្ធ ឬអាទិទេពណាមួយនៅតាមកម្មវិធីបន់ស្រន់ក្នុងព្រះបរមរាជវាំងតែប៉ុណ្ណោះ។

សម្ដេចព្រះរាជបុត្រី ព្រះរាម នរោត្តម បុប្ផាទេវី មានព្រះសវនីយបន្តថា ក្រោយៗមកព្រះរាជាសព្វព្រះហឫទ័យ ឲ្យមានការសម្ដែងរបាំនេះជាសាធារណៈ ជាពិសេសក្នុងអំឡុងទស្សវត្សទី៦០ ក្នុងរាជ្យព្រះបាទ នរោត្តម សីហនុ ព្រះបរមរតនកោដ ទ្រង់សព្វព្រះហឫទ័យផ្លាស់ប្ដូរឲ្យមានការសម្ដែងរបាំព្រះរាជទ្រព្យ ជាសាធារណៈទាំងក្នុង និងក្រៅប្រទេស មកដល់បច្ចុប្បន្ននេះ។



*ការផាត់គុបតែងមុខតួអង្គមុនការសម្ដែង។ រូបភាពៈ សហការី*

សម្ដេចព្រះរាជបុត្រី ព្រះរាម នរោត្តម បុប្ផាទេវី៖ «ព្រះករុណាព្រះបាទស៊ីសុវត្ថិ ទ្រង់ដឹកនាំល្ខោនព្រះរាជទ្រព្យជាលើកទី១ នៅប្រទេសបារាំង ក្នុងឆ្នាំ១៩០៦។ ចឹងមានន័យថា យើងបានចេញម្ដងដែរក្នុងឆ្នាំ ១៩០៦។ ចាស! មិនមែនឥឡូវៗនេះដែរ ខ្ញុំមានភព្វាសនាដែរ ដែលខ្ញុំទទួលមរតកបន្តពីឪពុកខ្ញុំ ពីជីដូនខ្ញុំ ខំធ្វើយ៉ាងណាដើម្បីផ្សព្វផ្សាយឲ្យវាទូលំទូលាយ។ សព្វថ្ងៃនេះ ល្ខោនព្រះរាជទ្រព្យត្រូវបានគេអញ្ជើញ២ទៅ៣ដងដែរ នៅប្រទេសអឺរ៉ុប ប្រទេសបារាំង»។

មានមុខងារជាទីប្រឹក្សា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សាស្ត្រាចារ្យសកលវិទ្យាល័យ ភូមិន្ទវិចិត្រ និងសិល្បៈ លោក ព្រឿង ឈាង បានឲ្យដឹងថា របាំព្រះរាជទ្រព្យដែលជាទម្រង់ស្ត្រីនេះ មានក្បាច់បាតធំបួន គឺនាងតំណាងតួស្រី ក្បាច់នាយរោងតំណាងតួប្រុស យក្សនិងក្បាច់ស្វាដែលសម្ដែងអមដោយចម្រៀង។ក្បាច់បាតទាំងបួននេះ ក៏ត្រូវបានបំបែកជាក្បាច់តូចៗជាច្រើនទៀត។

សម្ដេចព្រះរាជបុត្រី ព្រះរាម នរោត្តម បុប្ផាទេវី មានព្រះសវនីយបញ្ជាក់ថា ក្បាច់មួយចំនួនត្រូវបានបាត់បង់ទៅតាមពេលវេលា៖ «ជាសំណាងដែរ របាំព្រះរាជទ្រព្យយើងជាសំណាង មិនបាត់បង់សោះ បាត់ក្បាច់ខ្លះពិតមែន។ ក្បាច់ទាំងអស់មានដល់ទៅជាង ២០០០ក្បាច់ឯណោះ តែឥឡូវនេះយើងមានតែជាង ៤០០ទៅ ៥០០ទេ។ ទោះបីជាមានតែប៉ុណ្ណោះក៏យើងត្រូវខំទៀត កុំឲ្យវាធ្លាក់ទៅទៀត»។

សម្ដេចព្រះរាជបុត្រី ព្រះរាម នរោត្តម បុប្ផាទេវី មានព្រះសវនីយបន្ថែមថា កូនសិស្សតូចៗដែលចូលមករៀននៅក្នុងសាលាវិចិត្រសិល្បៈ ដំបូងត្រូវរៀនហាត់ពត់ដៃជើង ហើយហាត់ក្បាច់បាតជាចាំបាច់ តែបើខ្លាំងឬតិច អាស្រ័យទៅតាមជំនាន់នីមួយៗ ក្បាច់នោះគឺវិវត្តន៍បន្តិចៗទេ តែបើក្បាច់បាតគឺនៅដដែលទេ។

សាស្ត្រាចារ្យ ផ្នែកវិចិត្រសិល្បៈទាំងពីរ រួមមាន សម្ដេចព្រះរាជបុត្រី ព្រះរាម នរោត្តម បុប្ផាទេវី និងលោក ព្រឿង ឈាង បានអះអាងថា របាំព្រះរាជទ្រព្យអាចបំបែកទៅជារបាំជាច្រើនទៀត រួមមាន របាំបួងសួង ល្ខោនខោល របាំអប្សរា និងរបាំទេពមនោរម្យ។

សិល្បការិនី មានភារៈសម្ដែងជាតួនាង និងជាមន្ត្រីនៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ កញ្ញា សេរីវណ្ណ កុសន បានឲ្យដឹងថា កញ្ញាឈានជើងចូលហាត់សិល្បៈតាំងពីអាយុ ៩ឆ្នាំ ដោយមានការជ្រោមជ្រែងពីគ្រួសារ និងមានចិត្តស្រឡាញ់សិល្បៈរបាំបុរាណខ្មែរ ជាពិសេស កញ្ញា ប្ដេជ្ញាថានឹងយកចំណេះដឹងនេះចែករំលែកទៅកាន់យុវជនជំនាន់ក្រោយបន្តទៀត។

កញ្ញា សេរីវណ្ណ កុសន៖ «យើងមានមោទនភាព ជាអ្នកបន្តវេននៃវប្បធម៌មួយ ដែលមានវ័យចំណាស់មួយរបស់ប្រទេសយើង។ ចឹង ពេលទៅស្រុកក្រៅ បរទេសគេសរសើរយើងសប្បាយចិត្ត ហើយនឹងបន្តចែករំលែកដល់អ្នកជំនាន់ក្រោយទៀត»។



*សម្ដេចព្រះរាជបុត្រី ព្រះរាម នរោត្តម បុប្ផាទេវី កំពុងបង្ហាត់បង្ហាញសិស្សរបស់ទ្រង់។ រូបភាពៈ សហការី*

កញ្ញា ទេព ពិសី ជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យមួយក្នុងរាជធានីភ្នំពេញ បានឲ្យដឹងថា កញ្ញាចូលចិត្ត និងចង់ទស្សនារបាំព្រះរាជទ្រព្យនេះណាស់ តែគួរឲ្យសោកស្ដាយ របាំនេះគេមិនសូវសម្ដែងច្រើននោះទេ ភាគច្រើនអ្នកដែលបានទស្សនារបាំនេះសុទ្ធសឹងជាមន្ត្រីជាន់ខ្ពស់ អ្នកមានមុខមាត់នៅក្នុងសង្គម ជាដើម។ បើទោះបីពេលខ្លះបានអញ្ជើញសិស្សនិស្សិតទៅទស្សនាក៏ពិតមែន ប៉ុន្តែមានលក្ខណៈមិនទូលាយដែរ ដោយសារសាលាជ្រើសរើសសិស្សនោះជាពិសេស។

លោក វណ្ណៈ ជាបុគ្គលិកក្រុមហ៊ុនមួយបានឲ្យដឹងដែរថា៖ «ខ្ញុំចូលចិត្តមើលការសម្ដែងរបាំនេះ ដោយសារតែជារបាំបុរាណដែលកម្រនឹងបានមើលណាស់ ណាមួយយើងជាខ្មែរគួរចូលរួមថែរក្សាវា (របាំព្រះរាជទ្រព្យ) ឲ្យបានគង់វង្ស»។

កាលពីឆ្នាំ២០០៣របាំព្រះរាជទ្រព្យ ត្រូវបាន អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ របស់អង្គការសហប្រជាជាតិ (UNESCO) សម្រេចបញ្ចូលក្នុងបញ្ជីបេតិកភ័ណ្ឌពិភពលោក ផ្នែកសម្បត្តិមនុស្សជាតិ។

គិតត្រឹមឆ្នាំ២០០៨ សាលាមធ្យមវិចិត្រសិល្បៈ និងសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ មានសិស្សចូលរៀនរបាំបុរាណខ្មែរ និងរបាំព្រះរាជទ្រព្យ រហូតចំនួនជាង៣០០នាក់៕



*សាសនិកសាសនាធំៗទាំងបីនៅកម្ពុជា ដង្ហែសារដោយថ្មើរជើងប្រឆាំងការជួញដូរមនុស្ស។*



*សម្ដេច ស ខេង និងមេដឹកនាំសាសនាទាំងអស់បង្ហោះសាររួមគ្នា។ រូបភាព៖ សម្បត្តិ*

# សាសនានៅកម្ពុជារួមគ្នាផ្សព្វផ្សាយប្រឆាំងការជួញដូរមនុស្ស

*ដោយ៖ កែវ កញ្ញា*

កាលពីថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១៩ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួងធម្មការនិងសាសនា និងអង្គការការីតាសកម្ពុជា ដោយមានការចូលរួមគាំទ្រពីថ្នាក់ដឹកនាំសាសនារួមមាន ព្រះពុទ្ធសាសនា ឥស្លាមសាសនា ព្រះសហគមន៍កាតូលិក និង គ្រីស្តបរិស័ទដំណឹងល្អ និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា បានរៀបចំរួមគ្នា នូវវេទិកាជាតិ អន្តរសាសនា លើកទី៣ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើប នៅមជ្ឈមណ្ឌលនិងពិពណ៌កោះពេជ្រ រាជធានីភ្នំពេញ។

កម្មវិធីនេះ ប្រារព្ធឡើងក្រោមអធិបតី របស់សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរួមនឹងសាសនិកសាសនាធំៗទាំងបីនៅកម្ពុជាប្រមាណ ១៧០០អង្គនាក់។

តំណាងសាសនានានា បាននាំគ្នាដង្ហែសារដោយថ្មើរជើងប្រមាណជា៣គីឡូម៉ែត្រ ពីស្តូបមិត្តភាពកម្ពុជា-វៀតណាម ទៅកាន់មជ្ឈមណ្ឌលនិងពិពណ៌កោះពេជ្រជាកន្លែងប្រារព្ធកម្មវិធី។

នៅក្នុងអង្គពិធីនោះ ឯកឧត្តម ហ៊ីម ឆែម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា មានប្រសាសន៍ថា គោលបំណងសំខាន់នៃវេទិកានេះគឺ ៖ ទី១. ដើម្បីលើកកម្ពស់សារៈសំខាន់នៃវេទិកាអន្តរសាសនា នៅព្រះរាជាណាចក្រកម្ពុជា ដែលបង្ហាញពីភាពសុខដុមនៃសាសនានៅក្នុងព្រះរាជាណាចក្រកម្ពុជា នាំមកនូវសន្តិភាពជាតិ ការគោរពសិទ្ធិមនុស្ស សេចក្តីថ្លៃថ្នូរ និងភាពរីកចម្រើនរបស់មនុស្សជាតិ។

ទី២. ដើម្បីបង្ហាញពីតួនាទីដ៏សំខាន់របស់ថ្នាក់ដឹកនាំសាសនាទាំងឡាយក្នុងការផ្សព្វផ្សាយ អប់រំនិងផ្តល់ ចំណេះដឹងដល់ប្រជាពលរដ្ឋ អំពីសីលធម៌ក្នុងការរស់នៅ ជៀសវាងការរំលោភបំពាន អំពើជួញដូរ កេងប្រវ័ញ្ចគ្រប់រូប ភាពលើមនុស្សផងគ្នានិងជួយណែនាំឲ្យចូលរួមបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងឈានទៅលុបបំបាត់អំពើជួញដូរ មនុស្ស ដែលជាទាសភាពសម័យទំនើបគួរឲ្យស្អប់ខ្ពើម។

និងទី៣ គឺដើម្បីឲ្យសំឡេងនៃការសូត្រធម៌អធិដ្ឋាននៃសាសនា ផ្តល់នូវក្តីសង្ឃឹមដល់ជនរងគ្រោះ អ្នកដែលរងទុក្ខដោយសារអំពើជួញដូរមនស្ស និងសូមឲ្យពួកគាត់ឆាប់ទទួលបានសេរីភាពឡើងវិញ។

លោកវេជ្ជបណ្ឌិត បេណាឌីប រ៉ូសារីយ៉ូ តំណាងអង្គការការីតាសអាស៊ីមានប្រសាសន៍ថា ជនរងគ្រោះនៃការជួញដូរភាគច្រើនគឺជាជនក្រីក្រ គ្មានចំណេះដឹង ដែលងាយស្រួលគេបោកបញ្ឆោត។«ភាពក្រីក្រជាសត្រូវរបស់យើង។ យើងអាចយកឈ្នះវាដោយផ្តល់ឲ្យមនុស្សមានការអប់រំ ទទួលបានសុខភាពល្អ ជីវភាពសមរម្យ និងមានការងារធ្វើប្រកបដោយជំនាញវិជ្ជាជីវៈ។ ហើយយើងទាំងអស់គ្នាត្រូវប្តេជ្ញាចិត្ត ដើម្បីឲ្យសង្គមគ្មានអ្នកក្រីក្រ»។



*ព្រះសហគមន៍កាតូលិក និង គ្រីស្តបរិស័ទដំណឹងល្អថតរូបអនុស្សាវរីយ រូបភាព៖ សម្បត្តិ*

លោកមានប្រសាសន៍ទៀតថា សព្វថ្ងៃនេះ ការីតាសនៅទូទាំងពិភពលោកធ្វើការងារក្នុងតំបន់ ដោយលើកស្ទួយនិងសហការណ៍រវាងការីតាសនិងការីតាស ការីតាសនិងដៃគូនានាទាំងរដ្ឋាភិបាលផង ដើម្បីលើកសេចក្តីថ្លៃថ្នូររបស់មនុស្ស និងធានាបាននូវកិច្ចការពារមួយដ៏ប្រសើរ។

នៅត្រង់ចំណុចនេះ សម្ដេច ស ខេង បានមានប្រសាសន៍ថា សាសានាទាំងអស់បានចូលរួមបង្ហាញពីចេតនាគាំទ្រយ៉ាងពេញទំហឹងទៅដល់គោលនយោបាយរបស់រដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ សម្ដេចក៏លើកទឹកចិត្តដល់សាសនាទាំងអស់ឲ្យយកចិត្តទុកដាក់ចូលរួមបន្ថែមទៀតក្នុងការបញ្ជ្រាបការយល់ដឹងអំពីការជួញដូរមនុស្សនេះដល់សាសនិករបស់ខ្លួន។

សម្ដេច ស ខេង៖ «ហើយអ្វីដែលយើងអាចធ្វើបានគឺ ការអប់រំផ្សព្វផ្សាយ ឲ្យមជ្ឈដ្ឋាននានានៅក្នុងសាសនារបស់យើង ប្រជាពលរដ្ឋដែលងាយរងគ្រោះបានយល់បានដឹងអំពី បែបផែនធ្វើសកម្មភាពរបស់ជនទុច្ចរិតក្នុងការជួញដូរ។... គឺខ្ញុំគិតថាពិតជាមានផលប្រយោជន៍»។

តាមរបាយការណ៍របស់លោកជំទាវ ជូ ប៊ុនអេង ថ្លែងក្នុងអង្គពិធី បានឲ្យដឹងថា កន្លងមកការបង្ក្រាបចំពោះអំពើជួញដូរបានចំនួន៧៨ករណី ដែលកើនឡើងជាងឆ្នាំ២០១៨ ១៦ករណី និងបានឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន៩៧នាក់។ ក្នុងនោះដែរក៏មានជនរងគ្រោះចំនួន២៦៣នាក់ ដែលកើនឡើង១៥៧នាក់ បើធៀបនឹងឆ្នាំ២០១៨។ ក្នុងចំណោមជនរងគ្រោះមានអាយុក្រោម១៥ឆ្នាំ ចំនួន៧០នាក់ អាយុ ១៥-១៧ឆ្នាំ ៣១នាក់ និងពី១៨ឆ្នាំឡើងទៅមានចំនួន១៦២នាក់។

លោកជំទាវឲ្យដឹងទៀតថា ជនរងគ្រោះ៧២នាក់ត្រូវបានបញ្ជូនទៅមន្ទីរសង្គមកិច្ច និងចំនួន ១៩១នាក់ផ្សេងទៀតបានប្រគល់ជូនគ្រួសាររបស់ពួកគេវិញ។

លោកជំទាវបន្ថែមថា ការងារចំណាកស្រុកក្រៅប្រទេសរបស់ពលកររកន្លងមក រដ្ឋាភិបាលបានធ្វើការសម្របសម្រួល និងបានផ្តល់ឯកសារផ្លូវច្បាប់ដើម្បីវិលត្រឡប់មកប្រទេសកម្ពុជាវិញ។ ភាគច្រើនពលករដែលត្រូវបានបញ្ជូនត្រឡប់មកពីប្រទេសថៃប្រមាណជា ជាង ២ម៉ឺននាក់ ដែលត្រូវនឹង៨៣,២១ភាគរយនៃពលករសរុប។

ក្នុងពេលកន្លងមកនេះ សពពលករដែលបញ្ជូនមកវិញជាផ្លូវការមានចំនួន៧១នាក់ ដោយមិនគិតពីសាកសពដែលត្រូវបានបូជា ឬមិនបានរាយការណ៍នៅតាមប្រទេសគោលដៅ។

មុនពេលបញ្ចប់កម្មវិធីសម្ដេច ស ខេង, លោកជំទាវ ជូ ប៊ុនអេង និងមេដឹកនាំសាសនាទាំងអស់បានបង្ហោះសាររួមគ្នាដើម្បីបញ្ជាក់អំពីចេតនានៃការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស៕



*លោកអភិបាល អេនរីគេ ហ្វីកាវេជូ (គីគេ) និងសម្ដេចព្រះសង្ឃរាជាធិបតី ប៊ូ គ្រី។ រូបភាព៖ សម្បត្តិ*

# វប្បធម៌ និងភាសាចិន នៅក្នុងសង្គមខ្មែរបច្ចុប្បន្ន



**គ្រួសារកូនចៅចិន ឬក៏ជនជាតិខ្មែរដែលមានជាប់សែស្រឡាយចិន មានកាន់តែច្រើននៅក្នុងសង្គមកម្ពុជាសព្វថ្ងៃនេះ។ ការរស់នៅដោយអនុវត្តតាមវប្បធម៌ចិនក៏មានការពេញនិយម រីឯការសិក្សារៀនសូត្រភាសាចិនរបស់កូនខ្មែរជំនាន់នេះក៏មានការកើនឡើងផងដែរ។**

*ដោយ៖ ផល សុផានិត*

ក្រៅអំពីការប្រារព្ធពិធីបុណ្យចូលឆ្នាំ ពិធីសែនលោកខែដូចនឹងប្រទេសចិន ការរៀបចំពិធីមង្គលការ និងពិធីតាមបែបសាសនាដទៃទៀតរបស់ចិន ក៏ទទួលបានការពេញនិយមខ្លាំងណាស់ដែរនៅក្នុងប្រទេសកម្ពុជា។

លោក ញ៉ៀប សុផល ហៅ វង្ស ម៉េង ជាសមាជិកម្នាក់របស់ត្រកូលអ៊ឹង នៅក្នុងប្រទេសកម្ពុជា និងជាប្រធានក្រុមម៉ុងសាយទី១ នៅរាជធានីភ្នំពេញ ក៏បានអះអាងដែរថា គ្រាន់តែរបបកម្ពុជាប្រជាធិបតេយ្យបញ្ចប់ទៅមិនបានប៉ុន្មានផង គ្រួសាររបស់លោកក៏បានរៀបចំបង្កើតក្រុមម៉ុងសាយឡើងវិញតែម្តង។

ការបង្កើតឡើងវិញនៅក្នុងឆ្នាំ ១៩៩៣ សម្របតាមបែបប្រពៃណីក្នុងរាជធានីភ្នំពេញ ពុំមែនជាកិច្ចការថ្មីថ្មោងរបស់ត្រកូលលោកនោះឡើយ។ គិតត្រឹមជំនាន់របស់លោក ម៉េង ដូនតារបស់លោកបានមករស់នៅក្នុងប្រទេសកម្ពុជា៦ជំនាន់មកហើយ។

លោក ញ៉ៀប សុផល និយាយថា៖ «មួយថ្ងៃៗកាន់តែជឿនលឿនទៅ គេក៏ហៅក្រុមម៉ុងសាយទៅសម្តែងកាន់តែច្រើន សម្តោធក៏គេហៅ ព្រោះជនជាតិចិនមកវិនិយោគច្រើនក្នុងប៉ុន្មានឆ្នាំនេះ កសិកម្មក៏មាន ការសាងសង់ វាគ្រប់ផ្នែក»។

បុរសជាសមាជិកត្រកូលអ៊ឹង បានបញ្ជាក់ទៀតថា បើតាមការអង្កេតរបស់លោកផ្ទាល់ មូលហេតុ សំខាន់ដែលធ្វើឱ្យវប្បធម៌ខ្មែរចិនងាយចុះសម្រុងគ្នា ដោយសារប្រទេសទាំងពីរ គឺកម្ពុជា និងចិន មានប្រវត្តិការទូតជាមួយគ្នាយូរលង់មកហើយ។ ពិធីបុណ្យប្រពៃណីចិនមួយចំនួនមានអត្ថន័យប្រហាក់ប្រហែលនឹងគ្នា។

លោក ញ៉ៀប សុផល និយាយថា៖ «បើខ្ញុំគិតវាមិនខុសគ្នាអីប៉ុន្មានទេ វាអាចរស់នៅចុះសម្រុងគ្នាបាន ប្រពៃណីខ្មែរ និងប្រពៃណីចិនដូចៗគ្នាទាំងអស់ បុណ្យអុំទូកចិនក៏មាន សែនផ្កាខ្មែរយើងភ្ជុំបិណ្ឌ គ្រាន់តែខុសតែថ្ងៃខែ»។

បុរសខាងលើយល់ឃើញថា បើគិតផ្តោតតែលើវប្បធម៌ ប្រពៃណីតែម្យ៉ាង ទោះបីកូនខ្មែរប្រកាន់ខ្ជាប់វប្បធម៌ខ្មែរ និងចិនដំណាលគ្នា ក៏ពុំផ្តល់ផលប៉ះពាល់អ្វីនោះទេ សំខាន់ការរស់នៅត្រូវមានសាមគ្គី យោគយល់អធ្យាស្រ័យឱ្យគ្នាទៅវិញទៅមក ហើយឆ្ពោះទៅរកភាពរីកចម្រើនទាំងអស់គ្នា។

លោក ញ៉ៀប សុផល៖ «ធម្មតាទេការផ្លាស់ប្តូរវប្បធម៌គ្នាវាមិនថយក្រោយនោះទេ វាកាន់តែជឿនលឿន កាន់តែទៅមុខដូចគ្នា ការរកស៊ីផ្លាស់ប្តូរគ្នា ១០ ឬ២០ឆ្នាំទៅមុខទៀតវាកាន់តែរុងរឿងមែនទែន វាកាន់តែខ្លាំងមែនទែន»។

លោកសាស្ត្រាចារ្យ សំបូរ វណ្ណារ៉ា បង្រៀនផ្នែកប្រវត្តិសាស្ត្របានឲ្យដឹងថា កម្ពុជា និងចិនបានភ្ជាប់ទំនាក់ទំនងគ្នាតាំងពីសតវត្សទី៣ នៃគ.ស បន្ទាប់ពីមហាក្សត្រខ្មែរ ព្រះនាមហ្វាន់ជីមាន់ បង្កើតនូវកំពង់ផែអន្តរជាតិដើម្បីបើកទទួលធ្វើពាណិជ្ជកម្មជាមួយសាសន៍ដទៃ។ ពេលនោះហើយដែលលំហូនៃជនជាតិចិនបានមកដល់។

លោកសាស្ត្រាចារ្យបន្ថែមថា បច្ចុប្បន្នយើងមិនអាចនិយាយថា ប្រទេសចិនមានឥទ្ធិពលមកលើកម្ពុជាបានទេ។ លោក វណ្ណារ៉ា៖ «ពាក្យថាឥទ្ធិពលខ្ញុំមិនចង់ប្រើទេ ព្រោះថាយើងអន់ជាងគេ។ ខ្ញុំបាននិយាយហើយ យើងចង់បានគេ យើងក្រយើងឃ្លាន យើងត្រូវការគេឲ្យ។ ចឹងកាលណាគេឲ្យកាលណា យើងឆ្ងាញ់យើងទទួលយក នេះមិនមែនឥទ្ធិពលទេ។ ចឹងយើងមានទំនោរដោយខ្លួនឯង យើងចង់បានគេដោយខ្លួនឯង ចឹងត្រូវគិតឡើងវិញមិនមែនគេខ្លាំងដោយសារយើងទៅរកគេនោះទេ។ បើគេខ្លាំងយើងទៅរកគេ បានគេមានឥទ្ធិពល»។

លោកសាស្ត្រាចារ្យបន្ថែមទៀតថា៖ «សម័យនេះ សតវត្សទី២១ហើយ មិនចង់ក៏គេមកដែរ នេះសម័យទំនាក់ទំនងសកលភាវូបពាណិជ្ជកម្ម ដូច្នេះយើងមាំខ្លួនឯងអត់ យើងខ្លាំងអត់?»

ទន្ទឹមនឹងការរីកសាយនៃវប្បធម៌ប្រពៃណីចិនកាន់តែខ្លាំងនៅក្នុងប្រទេសកម្ពុជា ចំនួននៃសាលារៀនភាសាចិនក៏មានច្រើនគួរឱ្យកត់សម្គាល់ផងដែរ។ តើកូនខ្មែរសិក្សាភាសាចិនក្នុងគោលបំណងបែបណាខ្លះ?

កញ្ញា ហួយ មីង ជាសិស្សសិក្សាភាសាចិននៅសាលាមួយក្បែរផ្សារអូឡាំពិក បាននិយាយថា៖ «ម៉ាក់ថារៀនភាសាចិនរកការងារបានធ្វើ មានការងារច្រើន អាចឡើងទៅចិនជាមួយប៉ាយកអីវ៉ាន់»។

កុមារា លឹម សុខសំណាងបាននិយាយថា៖ «រៀនចិនរៀនយូរទៅមានអនាគត។ ម៉ាក់ខ្ញុំគាត់កាត់ចិន តែប៉ាមិនកាត់ទេ។ បានខ្ញុំសម្រេចចិត្តទៅរៀនចិន ដើម្បីគិតថា ពេលខ្ញុំធំឡើងខ្ញុំអាចបកប្រែឱ្យគេបាន»។

អតីតសិស្សសាលាភាសាចិនម្នាក់ឈ្មោះថា លី ឆាយ និយាយថា «ភាសានិងអក្សរចិនគឺត្រូវចំណាំអក្សរ តែភាសាខ្មែររៀនប្រកប។ បើយើងចេះភាសាចិន យើងអាចរកប្រាក់ខែបានច្រើនជាងអត់ចេះភាសាចិន» ។

ថ្វីត្បិតតែការចេះភាសាចិនជាចំណែកមួយដែលគ្រួសារខ្មែរមួយចំនួនបានគិតថា ជាការជួយរុញច្រានជីវិតរបស់កូនៗរបស់ពួកគាត់ ឆ្ពោះទៅអនាគតល្អប្រសើរ តែសាស្ត្រាចារ្យដែលបង្រៀននៅសាលាអន្តរជាតិមួយចំនួនបានយល់ឃើញថា **ភាសាបរទេសគ្រាន់តែជាភាសាយាន តែបើបំភ្លេចចោលភាសាជាតិក៏មិនមែនជាជំហានត្រឹមត្រូវនោះដែរ។**

សាស្ត្រាចារ្យ សួន សុភា ជាមន្ត្រីបម្រើការងារនៅវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិតសភាកម្ពុជាបានពោលថា បើសិនជាយើងមិនបានរៀនភាសាខ្មែរយើងឱ្យបានជ្រាលជ្រៅនោះទេ ដែលយើងហៅថា ភាសាជាតិតំណាងឱ្យខ្មែរយើង ជាអត្តសញ្ញាណជាតិខ្មែរយើងនោះទេ ថ្ងៃក្រោយយើងនឹងបាត់បង់ហើយ។

លោកបន្ថែមថា យើងឃើញថា កូនខ្មែរយើងបច្ចុប្បន្ននេះ មិនពេញនិយមអក្សរសាស្ត្រជាតិយើងនោះទេ ចឹងវាជាការសោកស្តាយមួយដែរ ប្រសិនបើយើងមិនប្រយ័ត្នទេ វាបាត់អត្តសញ្ញាណរបស់យើងជាកូនខ្មែរ ហើយកូនខ្មែរភាគច្រើននឹងបាត់ស្នេហាជាតិ ស្នេហាវប្បធម៌ ដែលធ្វើឱ្យយើងក្លាយទៅជាកូនកាត់ ឬកាឡៃ។

ទំនាក់ទំនងខ្មែរចិនមិនមែនជារឿងថ្មីនោះទេកំណត់ត្រាប្រវត្តិសាស្ត្រជាច្រើនបានបញ្ជាក់ច្បាស់ពីទំនាក់ទំនងការទូត និងទំនាក់ទំនងរវាងប្រទេសទាំងពីរ។ ជាក់ស្តែងការទាក់ទងផ្នែកការទូតរវាង អាណាចក្រខ្មែរ និងចិន នៅសម័យបុរាណ បេសកជនចិន លោកជីវតាក្វាន់ បានធ្វើការកត់ត្រាអំពីប្រពៃណី អ្នកស្រុកចេនឡា តម្កល់ទុកក្នុងសៀវភៅប្រវត្តិសាស្ត្ររបស់ខ្លួន ក្នុងរាជ្យវង្ស ម៉ុងហ្គោលជាដើម៕



*ការរៀបចំសែនព្រេនបែបចិន។ រូបភាព៖ សហការី*




*សាលាបង្រៀនភាសាចិន ដែលបើកបង្រៀនក្នុងរាជធានីភ្នំពេញ។*



# កម្មករសំណង់លើកឡើងពីការខ្លាចរអារអំពី ការដ្ឋានខ្ពស់ៗនៅក្នុងប្រទេស

*ដោយ៖ អររិយបុត្រ*

ក្រោយពេលដែលកម្មករ និងកម្មការនីសំណង់ជាង៥៤ នាក់បានស្លាប់ និងរបួសដោយសារតែការបាក់រលំអគារនៅឯខេត្តព្រះសីហនុ កាលពីពេលថ្មីៗកន្លងទៅនេះ កម្មករ និងកម្មការិនីសំណង់មួយចំនួនបានលើកឡើងពីអារម្មណ៍ខ្លាចរអារបស់ពួកគេនៅការដ្ឋានសំណង់ខ្ពស់ៗ។

លោក ចេង សំអាង ដែលអះអាងថា ជាកម្មករសំណង់នៅការដ្ឋានសំណង់ខ្ពស់មួយនៅម្តុំទួលគោក បានឲ្យដឹងថា លោកមានអារម្មណ៍ដូចជារអើលនៅក្រោយពេលដែលបានឮ និងបានទទួលព័ត៌មាន អំពីការបាក់សំណង់សង្កត់មនុស្សស្លាប់នៅខេត្តព្រះសីហនុ។

លោក សំអាង ដែលបានអះអាងថា ធ្លាប់ដើរធ្វើជាកម្មករសំណង់នេះ ជាង ១០ឆ្នាំ នៅការដ្ឋានជាច្រើន បានរអ៊ូរទាំថា នៅការដ្ឋានរឿងសុវត្ថិភាពកម្មករ និងកម្មការនីនៅការដ្ឋាន ហាក់ដូចជាមិនសូវ មានការយកចិត្តទុកដាក់ខ្ពស់ឡើយ។

លោកបានបន្តទៀតថា ដោយសារតែភាពប្រថុយប្រថានបែបនេះ លោកកំពុងតែរិះរក និងបែកគំនិត ដេញថ្លៃការដ្ឋានណាដែលធ្វើការទាបៗជំនួសវិញ។

លោកបានបញ្ជាក់ថា៖ «ពេលបម្រើការនៅការដ្ឋាន គឺជីវិតត្រូវយកទៅផ្ញើនៅទីនោះហើយ»។ លោកបានរៀបរាប់ថា កន្លងមកពេលខ្លះ នៅការដ្ឋានខ្លះ ពេលធ្វើការគឺគ្មានទាំងមួកគ្មានទាំងខ្សែក្រវាត់ឲ្យផង ពេលឡើង ឬ បំពេញការងារនៅការដ្ឋាន ១០ ទៅ ២០ ជាន់អីនោះ។

នេះគឺជាការលើកឡើងរបស់កម្មករមួយរូបដោយឡែក លោក ថៃ សក្កដា ដែលជាកម្មករមួយរូប បាននិយាយនៅបេនឡានក្រុង មួយកន្លែងនៅក្រោយពេលត្រឡប់មកពីធ្វើការនៅខេត្តព្រះសីហនុវិញថា លោកបាត់អារម្មណ៍អស់រលីងនៅពេលដែលឮព័ត៌មានបាក់អគារកំពស់ ៧ជាន់នៅខេត្ត ព្រះសីហនុ នេះ។

លោកបានអះអាងថា តាំងពីដើមឆ្នាំមកដល់ពេលនេះ គឺលោកបានធ្វើជាកម្មករសំណង់នៅខេត្ត ព្រះសីហនុរហូត ដោយសារតែទីនោះសំបូរការងារ ហើយគេឲ្យលុយពលកម្មរាងច្រើន តែពេលខ្លះ គឺគ្រោះថ្នាក់ដោយសារតែត្រូវធ្វើការនៅកន្លែងដែលខ្ពស់ៗ បើមិនចឹងទេ គឺធ្វើការនៅក្រោមដីតែម្តង។



*វិស័យសំណាង់ និងអគារខ្ពស់ៗកំពុងសាងសង់។ រូបភាព៖ ស៊ីអេសស៊ី*

នៅក្នុងនាមជាកម្មករពេលខ្លះគឺត្រូវធ្វើការនៅលើសំណង់ទាំងនោះទាំងថ្ងៃទាំងយប់ ពោលគឺស៊ីចុកបុកទំពារ ហើយជុះអីសឹងតែនៅលើហ្នឹងតែម្តង។ ដល់ពេលដែលឮរឿងបាក់សង្កត់មនុស្សខ្ញុំដូចជាបាក់ស្បាតតែម្តង។

សក្កដា ដែលជាកម្មករសំណង់មកពីខេត្តស្វាយរៀង បានលើកឡើងថា ពីមុនលោកបម្រើការងារ តែតាមការដ្ឋានផ្ទះល្វែងអីទេ ប៉ុន្តែកាលពីដើមឆ្នាំ មិត្តភក្តិបបួលទៅកំពង់សោម ( ខេត្តព្រះសីហនុ ) ក៏ទៅនឹងគេ ហើយគឺបានលុយច្រើនមែន។ លោកបន្តថា ធ្វើជាជាងសំណង់រៀបឥដ្ឋនៅការដ្ឋាន នៅតាមបុរី មួយថ្ងៃបាន ១០ ដុល្លារអីច្រើន ហើយគេថា ឈ្នួលកម្មករថ្លៃហើយ តែពេលលោកទៅ ធ្វើការនៅការដ្ឋាននៅខេត្តព្រះសីហនុ គឺបាន ពី ១៥ ទៅ ១៨ ដុល្លារពេលខ្លះ ២០ ដុល្លារក៏មានដែរ គ្រាន់តែទីនោះវាការងារច្រើន ហើយហាត់ និងគ្រោះថ្នាក់បន្តិច។

នៅពេលដែលនិយាយដល់ទិដ្ឋភាពសោកនាដកម្មនៃការបាក់រលំអាគារ កំពស់ ៧ ជាន់នៅខេត្ត ព្រះសីហនុ នេះលោក សក្កដា បានរៀបរាប់ថា លោកដូចជាបាត់ព្រលឹងអស់រលីង។

លោកបានបញ្ជាក់ថា៖ «ពេលដែលទទួលព័ត៌មានថា បាក់ ខ្ញុំដែលនៅម្តុំតោពីរ គឺបាននាំគ្នាទៅមើលភ្លាមៗ ហើយពេលឃើញរន្ធត់ទន់ដៃទន់ជើងតែម្តង»។

ជុំវិញរឿងអារម្មណ៍នេះ លោក ចេង សំអាង បានឲ្យដឹងថា នៅមុនពេលកើតមានរឿងរលំអគារនេះ លោកក៏មានគម្រោងចង់ទៅធ្វើការនៅខេត្តព្រះសីហនុ នឹងគេដែរ ប៉ុន្តែឥឡូវនេះមិនបាច់ហៅទេ។

លោកបានបញ្ជាក់ថា៖ «ឥឡូវនេះហៅទៅឲ្យប៉ុន្មានក៏លែងចង់ទៅដែរ សុខចិត្តដើរម៉ៅការគេរៀបជញ្ជាំង រៀបឥដ្ឋរបងផ្ទះគេវិញស្រណុកចិត្តហើយស្រួលយកលុយជាង»។

លោក រិន ចាន់រិទ្ធ ដែលជាកម្មករភ្លើងមួយរូប បានចែករំលែកថា អារឿងធ្វើការនៅការដ្ឋានអគារខ្ពស់ៗនេះ គឺវាគ្រោះថ្នាក់ខ្លាំងណាស់ មិនថាការងារសំណង់ ការងារបណ្តាញអគ្គិសនី ឬ ទឹកអ្វីនោះទេ គឺយ៉ាប់ទាំងអស់។

ដើម្បីបញ្ចៀសនូវគ្រោះថ្នាក់ លោក រិន ចាន់រិទ្ធ ដែលជា កម្មករជំនាញមួយរូបបានជូនជាយោបល់ថា ដើម្បីសុវត្ថិភាពរបស់ខ្លួនកម្មករ និងកម្មការិនី គឺត្រូវតែរកក្រុមហ៊ុនណាដែលមានច្បាប់ មានឯកសណ្ឋាន មានស្តង់ដារសុវត្ថិភាពខ្ពស់។ ប៉ុន្តែ លោក ចេង សំអាង និង ថៃ សក្កដា បានត្អូញត្អែរថា៖ «ជាកម្មករសំណង់យើងទៅសុំការងារគេធ្វើ បើយើងទៅសុំគេរឿងច្បាប់ទម្លាប់គេឲ្យយើងមើលដែរ? ហើយគេឲ្យការងារយើងធ្វើដែរ?»។

ជុំវិញបញ្ហាសុវត្ថិភាពនៃសំណង់នេះ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់កំពុងតែយកចិត្តទុកដាក់។

លោក ជា សុផារ៉ា ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានថ្លែងក្រោយពេលដែលកើតមានហេតុការណ៍បាក់រលំអគារនៅខេត្តព្រះសីហនុថា ក្រសួងនឹងចាត់វិធានការ ដើម្បីធ្វើកិច្ចការនេះ។

ថ្លែងនៅក្នុងពេលជួបជាមួយនឹងក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ចំនួន ១៦៥ ក្រុមហ៊ុន កាលពីពេលថ្មីៗនេះលោក ជា សុផារ៉ា ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានប្រកាសថា ចាប់ពីពេលនេះតទៅ សំណង់ដែលគ្មានច្បាប់ត្រឹមត្រូវ គឺមិនអនុញ្ញាតឲ្យចូលស្នាក់នៅ មិនអនុញ្ញាតឲ្យធ្វើអាជីវកម្ម មិនតទឹក និងតភ្លើងជូនឡើយ។

ការដាក់កំហិតបែបនេះ គឺបន្ទាប់ពីកើតមានឧប្បត្តិហេតុបាក់រលំអគារកម្ពស់៧ជាន់ នៅខេត្តព្រះសីហនុ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ ដែលបានបណ្តាលឲ្យមនុស្សចំនួន២៨នាក់ស្លាប់ និងរងរបួសចំនួន២៦នាក់។

រហូតមកដល់ពេលនេះ គណៈកម្មការអន្តរក្រសួងមួយបានបង្កើតឡើង ដើម្បីសិក្សា និងស៊ើបអង្កេត ស្ថានភាព និងគុណភាពនៃការដ្ឋានសំណង់នៅខេត្តព្រះសីហនុ ដែលគេដឹងថា គឺជាទឹកដីដែល សំណង់នៅទីនោះកំពុងតែច្របូកច្របល់៕

# គ្រឿងញៀន វាយលុកសង្គមកម្ពុជាខ្លាំង! ពលរដ្ឋកំពុងតែព្រួយបារម្ភ

ប្រជាពលរដ្ឋកម្ពុជាកាន់តែមានការព្រួយបារម្ភខ្លាំងនឹងការរីករាលដាលគ្រឿងញៀនគ្រប់ប្រភេទ ដែលមានវត្តមាននៅកម្ពុជា បើទោះបីជាអាជ្ញាធរបានរាយការណ៍ពីករណីបង្ក្រាបសឹងតែជារៀងរាល់ថ្ងៃក៏ដោយ។

*ដោយ៖ អរិយបុត្រ*







*ជនសង្ស័យជួញដូរថ្នាំញៀន និងអ្នកប្រើប្រាស់ថ្នាំញៀនផ្សេងៗដែលត្រូវបានសមត្ថកិច្ចបង្ក្រាបបាននាពេលកន្លងមក។ រូបភាព៖ គេហទំព័រនគរបាលជាតិ*

តាមរបាយការណ៍របស់សមត្ថកិច្ចដែលបានផ្សព្វផ្សាយកន្លងមក កន្លែងលក់ និងចែកចាយគ្រឿងញៀន គឺមានសឹងតែដូចជាកន្លែងលក់ចាប់ហួយនៅតាមភូមិ តាមសហគមន៍ នៅភូមិស្រុកនានា នៅក្នុងប្រទេសទៅហើយនោះ។

លោករិន សារឿនជាប្រជាពលរដ្ឋមួយរូបបានឲ្យដឹងថា គ្រឿងញៀនពិតជាបង្កបញ្ហាសង្គមដែលគួរឲ្យព្រួយបារម្ភមែនទែន ដោយសារតែវាត្រូវបានលក់ និងចែកចាយយ៉ាងទូលំទូលាយ នៅទូទាំងប្រទេស។

លោកបានបញ្ជាក់ថា៖ «ខ្ញុំមិនដឹងថា គ្រឿងញៀនវាមានស្អីខ្លះទេ ប៉ុន្តែព័ត៌មានចែកចាយ ហើយឃើញគេចែកចាយ និងប្រើប្រាស់នៅនឹងមុខៗ សឹងតែគ្រប់កន្លែង»។

លោក ទិន យ៉ារ៉ាវិទ្ធ ជាបុគ្គលិកនៃក្រុមហ៊ុនឯកជនមួយ បានថ្លែងថា យើងមិនប្រើយើងមិនដឹងថា រឿងនេះវាធ្ងន់ធ្ងរទេ តែលោកមានមិត្តភក្តិដែលប្រើប្រាស់គេធ្លាប់ប្រាប់លោកថា គ្រាន់តែតេតាមទូរសព្ទក៏មានអ្នកយកមកឲ្យដែរ។

អ្នករត់ម៉ូតូកង់បីឥណ្ឌាមួយរូបបានថ្លែងនៅក្នុងលក្ខខណ្ឌអនាមិកមួយរូបថា មិនខ្វះទេពួកអ្នកលក់គ្រឿងញៀន។

លោកបានបន្តថា សព្វថ្ងៃនេះកន្លែងណាក៏ដូចជាលោកធ្លាប់ឃើញមានគេជួញដូរដែរ។

អ្នករត់កង់បីឥណ្ឌារូបនោះ បានថ្លែងបញ្ជាក់ថា «តាមបា តាមណាយក្លឹប តាមខារ៉ាអូខេ តាមសហគមន៍ក្រីក្រ ខ្ញុំឃើញគេជួញដូរតែញយៗ»។

លោកបានបន្តទៀតថា ពេលខ្លះគ្មានទាំងលាក់លៀមស្អីទេ គឺហុចទៅហុចមក ដូចទិញបារី ទិញស្ករកៅស៊ូផងក៏មានដែរ។

ទាំងនេះគឺជាការលើកឡើងរបស់ប្រជាពលរដ្ឋ ប៉ុន្តែខាងសមត្ថកិច្ចក៏បានលើកឡើងដែរអំពីការព្រួយបារម្ភ ហើយក៏កំពុងតែជំរុញ និងពង្រឹងយុទ្ធនាការបង្ក្រាបគ្រឿងញៀននេះ។

នាយឧត្តមសេនីយ៍ មាស វីរិទ្ធ អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានថ្លែងថា ប្រទេសកម្ពុជាមានភូមិសាស្ត្រនៅជិតតំបន់ត្រីកោណមាស និងអឌ្ឍច័ន្ទមាស ដែលធ្វើឲ្យកម្ពុជា នៅតែប្រឈមទៅនឹងបញ្ហាគ្រឿងញៀន។

លោកបានថ្លែងថា គ្រឿងញៀនជាបញ្ហាសង្គមដ៏ស្មុគស្មាញ សម្រាប់សង្គមមនុស្សជាតិទាំងមូល ដូច្នេះហើយបានជាអាជ្ញាធរកំពុងតែបន្តយកចិត្តទុកដាក់លុបបំបាត់ឲ្យបានទាំងស្រុងនូវរាល់បទល្មើស ជួញដូរប្រើប្រាស់គ្រឿងញៀនទាំងនេះ។

លោកបន្តថា នៅឆ្នាំ ២០១៩ នេះ តាមគោលការណ៍ គឺអាជ្ញាធរមានគម្រោងនឹងលុបបំបាត់វានៅតាមក្លឹប កំសាន្ត និង ទីសប្បាយដ្ឋាននានា។

តាមរបាយការណ៍របស់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបង្ហាញថា ក្នុងរយៈពេល ៥ខែ ឆ្នាំ ២០១៩កន្លងទៅនេះកម្លាំងអនុវត្តច្បាប់បានធ្វើការបង្ក្រាបបទល្មើសគ្រឿងញៀន សរុបចំនួន ៣.៣៣៥ ករណី ដោយឃាត់ខ្លួន ៧.០៩៧នាក់ ចាប់យកសារធាតុញៀនគ្រប់ប្រភេទសរុប ៣១០ គីឡូក្រាមនៅក្នុងនោះមាន កញ្ឆាស្រស់ ៤៧.១០៣ដើម រួមនឹងមធ្យោបាយសម្ភារៈវត្ថុតាងមួយចំនួនទៀត។

ប្រភពដដែលបានបន្តទៀតថា ករណីជួញដូរ ត្រូវបានសមត្ថកិច្ចបង្ក្រាបចំនួន ២.០៣៩ករណី ដោយឃាត់ខ្លួន ៣.៨៧៣ នាក់ ដោយឡែកករណីប្រើប្រាស់ មាន១.២៧៦ករណី និងឃាត់ខ្លួន ៣.២២០នាក់ ហើយសមត្ថកិច្ចបានកសាង សំណុំរឿងបញ្ជូនទៅតុលាការចំនួន ២៣២នាក់ បញ្ជូនទៅមណ្ឌលព្យាបាល និងស្តារនីតិសម្បទាចំនួន ២.១០៥នាក់ និងអប់រំធ្វើកិច្ចសន្យាប្រគល់ជូនអាណាព្យាបាលយកទៅព្យាបាលបន្សាបនៅតាមសហគមន៍ចំនួន ៨៨៣នាក់។ ដោយឡែកសមត្ថកិច្ចបានអនុវត្តដីកាបាន ១១០ដីកា និងឃាត់ខ្លួន ១០៩នាក់។ សកម្មភាពបង្កករណីធំៗ ដែលមានសារធាតុញៀនចាប់ពី ១គីឡូក្រាម ឡើងទៅមានចំនួន២០ករណី ចាប់យកសារធាតុញៀនសរុប ២៨៨,៣៨ គីឡូក្រាម និងចាប់បានមេក្លោងចំនួន ១២នាក់ ខ្សែរយៈបណ្តាញចំនួន ៥២នាក់៕



*អ្នកប្រើប្រាស់ថ្នាំញៀនក្នុងរយៈពេលយូរហួតដល់បាត់បង់សតិ និងអាចក្លាយជាជនអនាថារស់នៅតាមទីសាធារណៈ។ រូបភាព៖ ស៊ីអេសស៊ី*

# សិល្បៈសៀកខ្មែរមិនសូវពេញនិយមសម្រាប់ពលរដ្ឋក្នុងស្រុក



យុវជនសម្តែងជូនភ្ញៀវទស្សនា។ រូបភាព៖ សហការី

**នៅពេលដែលវិស័យនានាមួយចំនួននៅក្នុងសង្គមខ្មែរបច្ចុប្បន្ននេះកំពុងតែមានការរីកចម្រើននោះ វិស័យសិល្បៈសៀកហាក់នៅទ្រឹងនៅឡើយ ។ ការមិនយល់ មិនគាំទ្រ មិនចូលរួម និងមិនឱ្យតំលៃសិល្បៈសៀកពីសង្គមគឺជាកត្តាចម្បងដែលធ្វើឱ្យសិល្បៈសៀក នៅប្រទេសកម្ពុជាមិនរីកចម្រើន ។ នេះជាការលើកឡើងរបស់សាស្ត្រាចារ្យផ្នែកសិល្បៈសៀកនៃសាលាសៀកជាតិ ។**

*ដោយ៖ ផល សុផានិត*

នៅក្នុងរោងសៀកស្ថិតនៅក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ សិល្បករ ដន សុធីវណ្ណ កំពុងលោត ហ្វឹកហាត់ជាមួយឧបករណ៍ ព្រមទាំងសិស្សដទៃទៀតដែលធ្វើការបង្ហាត់បង្រៀនដោយសាស្ត្រាចារ្យបរទេសមួយរូប។ សិស្សវ័យ២០ឆ្នាំរូបនេះ បានចូលសិក្សាផ្នែកសៀក នៅសាលាជាតិសៀក អស់រយៈពេល៨ឆ្នាំមកហើយ។ សំរាប់លោក ដន សុធីវណ្ណ ជារឿងចៃដន្យដែលនាំឱ្យរូបគេចូលហាត់រៀនសិល្បៈសៀកនៅទីនេះ។

លោក ដន សុធីវណ្ណ «ពីដំបូងខ្ញុំមិនទាន់ដឹងថាសៀកនេះជាអ្វីនោះទេ ប៉ុន្តែបានបងខ្ញុំម្នាក់។ បងស្រីខ្ញុំគាត់បានហាត់សៀក ដល់ពេលអីចឹងទៅ គាត់នាំខ្ញុំទៅមើលសៀកជាមួយគាត់។ ដល់ពេលខ្ញុំឃើញសៀក ខ្ញុំគិតថាមនុស្សដទៃមិនអាចងាយធ្វើបាននោះទេ។ មិត្តភក្តិហើយនិងបងប្អូន ឃើញថាសៀកនេះអស្ចារ្យក៏ជួយជំរុញ ឱ្យខ្ញុំមានទឹកចិត្តចូលហាត់សិល្បៈសៀក»។

សុធីវណ្ណ មិនបានដឹងថាតើនៅថ្ងៃអនាគត មានអ្នកគាំទ្រវិស័យសិល្បៈសៀកនេះកម្រិតណានោះទេ។

លោកស្រី ភោគ ណារិន នាយិកាសាលាសៀកជាតិ មានប្រសាសន៍ទទួលស្គាល់ថាវិស័យសៀក នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ននេះ មិនទាន់រីកចម្រើននៅឡើយនោះទេ ដោយសារតែមហាជនខ្មែរមិនទាន់យល់ មិនទាន់ស្គាល់ និងមិនទាន់ឱ្យតំលៃសិល្បៈសៀករបស់ជាតិខ្លួន។ នៅពេលដែលមិនមានការគាំទ្របែបនេះចំនួនសិស្សចូលហាត់សៀកកាន់តែតិចទៅៗរហូតលែងមានតែម្តង។ ទាំងនេះជាការលើកឡើងរបស់នាយិកាសាលាសៀកជាតិ។

នាយិកា សាលាសៀកជាតិ លោកស្រី ភោគ ណារិន «នៅពេលប៉ុន្មានឆ្នាំមុនៗមកយើងមានសិស្សចូលរៀនច្រើន ដូចថាមួយឆ្នាំមានពី២០ ទៅ ៣០នាក់។ តែនៅប៉ុន្មានឆ្នាំចុងក្រោយនេះ ឆ្នាំសិក្សា២០១៥ ២០១៦ សាលាសៀកយើងដាច់បាត់តែម្តង គឺគ្មានសិស្សចូលរៀននោះទេ ដោយសារទី១ នៅពេលដែលយើងរៀនចប់ កូនសិស្សទាំងអស់ពិបាករកការងារធ្វើ។ ឧទាហរណ៍គាត់ចង់បង្កើតការសម្តែងណាមួយ វាខ្វះការគាំទ្រច្រើន»។

ប្រាកដណាស់គឺខ្វះការគាំទ្របច្ចេកទេស សម្ភារ ថវិកា និងទីតាំងហាត់រៀនការសម្តែង។

លោកស្រី ភោគ ណារិន ពន្យល់លម្អិតថា កង្វះអ្នកជំនាញទីផ្សារក្នុងការស្វែងរកអ្នកជួយឧបត្ថម្ភការសម្តែងរបស់សិស្ស ក៏ជាផ្នែកមួយមិនអាចរីកចម្រើន។ ចំណែកឯមហាជនក៏គ្មានឱកាសទស្សនា និងស្គាល់សិល្បៈសៀកខ្មែរដែរ។

លោកស្រី ភោគ ណារិន «ខ្ញុំមានបទពិសោធច្រើន នៅពេលដែលយើងមានកម្មវិធីជាតិ ដូចជាកម្មវិធី អុំទូក ឬកម្មវិធីផ្សេងៗ ក្រសួងវប្បធម៌បានរៀបចំ ឱ្យសាលាសៀក ជាមួយនឹងរបាំដាក់បង្ហាញជូនប្រជាជនយើងដើម្បីបានទស្សនាគឺការសម្តែងទាំងអស់នោះ ការសម្តែងសៀកមានការលេចធ្លោច្រើនជាងគេ ប៉ុន្តែនៅពេលដែលមានការទិញសំបុត្រគឺមិនសូវពេញនិយម»។

សាលាសៀកជាតិ ដែលចំនុះឱ្យសាលាមធ្យមសិក្សាវិចិត្រសិល្បៈត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៨១។ សិស្សត្រូវសិក្សាហាត់រៀននៅសាលានេះរយៈពេល៩ឆ្នាំមុននឹងទទួលបានសាលាបត្រសិល្បៈសៀកដែលទទួលស្គាល់ដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

លោក ឡុង ម៉េងហៀង ជាប្រជាពលរដ្ឋមួយរូបឲ្យដឹងថា ដោយសារការចូលទស្សនាសៀកគឺត្រូវបង់ប្រាក់ក្នុងតម្លៃមួយថ្លៃ ហើយម៉្យាងទៀតសម្ភារៈសម្តែងគឺមិនសូវទំនើប ឬសំប្តូរបែបដែលធ្វើឲ្យការសម្តែងមិនសូវរស់រវើក។

អ្នកនាង សួន បញ្ញាលីន ជាបុគ្គលិកក្រុមហ៊ុនមួយក្នុងរាជធានីភ្នំពេញឲ្យដឹងថា គាត់ចូលចិត្តសិល្បៈសៀកនេះ ហើយពេលទំនេរគាត់ទៅមើលគេហាត់នៅសាលាសិល្បៈ និងមើលតាមទូរទស្សន៍ខ្លះ។

បញ្ញាលីន៖ «វា( សៀក )ល្អមើលពេលខ្លះក៏វាធ្វើឲ្យយើងស្លុងចិត្តទៅតាមនេះ តែវាក៏គួរឲ្យខ្លាចដែរ( លោតហាក់) ធ្វើឲ្យយើងមានអារម្មណ៍រន្ធត់ទៅតាមនោះ ហើយក៏ធ្វើឲ្យយើងចង់តាមដានដែរ»។

រីឯលោក រិន នីរ៉ាត់ និយាយថាសំរាប់គាត់ចូលចិត្តមើលសៀក ហើយក៏គាំទ្រដែរ ប៉ុន្តែសំរាប់អ្នកសម្តែងសៀកខ្មែរវិញ បច្ចុប្បន្នស្ទើរតែបាត់ទៅហើយ។ គាត់បន្តថា មិនដែលទៅមើលនៅតាមរោងមហោស្រប ឬឆាកសម្តែងដែលមានលក់សំបុត្រទេ ភាគច្រើនមើលតាមប្រព័ន្ធផ្សព្វផ្សាយ និងការសម្តែងនៅទីសាធារណៈ ដូចដែលគេហៅថា លេងប៉ាហ៊ីប៉ុណ្ណោះ។

យ៉ាងណាមិញ សិល្បៈមួយបែបនេះត្រូវបានពេញនិយមពីសំណាក់បរទេសទៅវិញ។ ជាពិសេសគឺភ្ញៀវដែលមកកំសាន្តនៅកម្ពុជា។ កាលពីពេលកន្លងទៅថ្មីៗនេះ មានការបង្ហាញអំពីសៀកសហសម័យដែលរៀបចំឡើងដោយសមាគមហ្វាពន្លឺសិល្បៈ ជាការបង្ហាញវប្បធម៌ រឹតចំណងមិត្តភាព រៀនពីគ្នាទៅវិញទៅមក។ ជាពិសេសគឺជាឱកាសឱ្យសិល្បករខ្មែរ ស្គាល់គ្នាជាមួយសិល្បករបរទេសមកពីប្រទេសចំនួន៥។

សិល្បករខ្មែរគឺមកពីសមាគមហ្វាពន្លឺសិល្បៈ និងសាលាសៀកជាតិ។ ការសម្តែងនេះ បានលក់សំបុត្រក្នុងតម្លៃពី៦-២០ដុល្លារអាមេរិក ហើយភ្ញៀវទស្សនាភាគច្រើនគឺជាជនបរទេស។

លោក ហួត តារា នាយកល្ខោនសៀកកម្ពុជានៃសមាគមហ្វាពន្លឺសិល្បៈ បានប្រាប់ថា មានភ្ញៀវទេសចរណ៍បរទេសជាច្រើនបានស្គាល់កម្ពុជា តាមរយៈការសម្តែងសៀកសហសម័យនេះពីសមាគមរបស់លោក។ ហើយសិល្បៈមួយនេះកំពុងនាំមុខគេក្នុងតំបន់អាស៊ីអាគ្នេយ៍។

លោក ហួត តារា៖ «ការនាំមុខគេនេះគឺគ្រប់ហេដ្ឋារចនាសម្ព័ន ដែលពាក់ព័ន្ធជាមួយសៀកសហសម័យ យើងមានទាំងសិល្បករជាច្រើន យើងមានទាំងអ្នកដឹកនាំរឿង និងអ្នកភ្លេង ( ភ្លេងបុរាណខ្មែរ) និងឧបករណ៍ភ្លេងទំនើប ដើម្បីបង្កើតជាសាច់ភ្លេងទំនើប មានទាំងទីតាំងឧបករណ៍ភ្លើង ឆាក ទាំងអស់នោះគឺមានសារៈសំខាន់ ដែលបង្កើតឱ្យមានភាពល្អឥតខ្ចោះឡើង»៕



# ស្ត្រីខ្មែរនៅតែមិនចោលហូលផាមួង

**ក្នុងពិធីធំៗរបស់ប្រជាជនខ្មែរ សំលៀកបំពាក់ដែលគេមើលឃើញជាទូទៅ គឺប្រើប្រាស់ហូល ផាមួង ឬ សូត្រដែលជាក្រណាត់ប្រពៃណីរបស់ជាតិ។ ក្បាច់រចនាម៉ូតនានាត្រូវបានបង្កើតឡើងជាច្រើនអនេក ជាពិសេសសម្រាប់មនុស្សស្រី។ ស្ត្រីខ្មែរមិនដែលបោះបង់ចោលកេរដំណែលនេះឡើយ ព្រោះ ពួកគាត់ យល់ឃើញថា វាមានតម្លៃ និងគួរត្រូវបានរក្សាទុកកុំបោះបង់។**

*ដោយ៖ រឿន ស្រីម៉ាច*



*រូបភាព៖ សីវេនដាយម៉ុន*

សម័យបច្ចុប្បន្ន បើទោះបីជាមានសម្លៀកបំពាក់ទំនើបៗច្រើនក្តី តែស្ត្រីខ្មែរនៅតែនិយមប្រើប្រាស់សម្លៀកបំពាក់ប្រពៃណីដែលធ្វើពីសូត្រ ហូល ផាមួងដែលជាក្រណាត់ ប្រពៃណី តាំងពីបុរាណដែលផលិតចេញពីហត្ថកម្មខ្មែរ។ របស់របបទាំងឡាយដែលផលិតពីក្រណាត់សូត្រខ្មែរនៅតែមានប្រជាប្រិយភាពពិសេសក្នុងពិធីអាពាហ៍ពិពាហ៍ បុណ្យជាតិ និងកម្មវិធីផ្សេងៗជាដើម។

កំពុងដើររើសសាច់ក្រណាត់ហូលដើម្បីឱ្យជាងកាត់សម្រាប់ចូលរួមពិធីមង្គលការក្មួយ អ្នកស្រី សុខ សុផារី វ័យ ៣៨ឆ្នាំ រស់នៅភ្នំពេញបានឱ្យដឹងថា៖ «ការចូលរួមពិធីផ្សេងៗគឺអ្នកស្រីតែងតែប្រើប្រាស់សម្លៀកបំពាក់ប្រពៃណី ព្រោះវាមើលទៅសមរម្យថ្លៃថ្នូរ និងសុភាពរាបសារ។ ចំណែកម៉ូតម៉ាកផ្សេងៗគឺអាស្រ័យទៅលើការស្រលាញ់ចូលចិត្តរបស់បុគ្គល។

អ្នកស្រី សុផារីបន្ថែមថា៖ «តាំងពីដើមមកខ្មែរយើងមិនដែលចោលទេខោអាវប្រពៃណី ព្រោះវាជាមរតករបស់ខ្មែរតាំងពីបុរាណកាលមក ថ្វីត្បិតតែវាមានតម្លៃថ្លៃបន្តិចតែសម្រាប់ខ្ញុំគឺស្រលាញ់ខ្លាំងនៅពេលយកវាមកគ្រងលើខ្លួនម្តងៗ គឺមានអារម្មណ៍ថាពេញចិត្ត និងមោទនភាពចំពោះខ្លួនឯងជាស្ត្រីខ្មែរ»។

ចំណែកកញ្ញា តុង លីកា វ័យ ២៥ឆ្នាំ មកពីខេត្តតាកែវ កំពុងបន្តការសិក្សានៅភ្នំពេញបានឱ្យដឹងថា៖ «នាងតែងតែជ្រើសរើសសំពត់អាវប៉ាក់សម្រាប់ទៅចូលរួមក្នុងពិធីហែជំនូន ពិធីមង្គលការ ឬ ពេលចូលរួមក្នុងពិធីបុណ្យផ្សេងៗព្រោះសមរម្យក្នុងការចូលរួមក្នុងពិធីទាំងនោះ។

លីកាបន្ថែមថា សព្វថ្ងៃនេះមានការច្នៃម៉ូតស្អាតៗជាច្រើន ហើយពណ៌វិញក៏ស្អាតៗដែរ ចឹងហើយមើលទៅគឺស្រលាញ់តែម្តង។ លីកា៖ «ម៉ាក់ប៉ា និងអ្នកផងតែងតែសរសើរថាស្អាត នៅពេលស្លៀកពាក់បែបប្រពៃណី ជាពិសេសជាស្ត្រីខ្មែរ ពុំគួរមើលរំលងហូល ផាមួង សូត្រ អាវប៉ាក់ឱនរបស់ខ្មែរ ព្រោះវាជាមរតករបស់ខ្មែរតាំងពីដើមមក»។

កញ្ញា លីកាបន្ថែមទៀតថា នាងទទួលស្គាល់ថាតម្លៃថ្លៃមួយក្បិនអាចលើសពី១០០ដុល្លារអាមេរិក ឬថោកជាងនេះ តាមសាច់ក្រណាត់។ ចំពោះម៉ូតខោអាវ អាចនឹងឆាប់សាំ គឺប្រើបានតែម្តងឬពីរដងប៉ុណ្ណោះ។ លីកា៖ «បើចំពោះខ្ញុំវិញ គឺយើងអាចកែច្នៃខ្លះៗ ដូចជាសំពត់ហូល ផាមួង ពណ៌អីក៏បានគឺប្រើជាមួយអាវប៉ាក់ពណ៌ស គឺមិនចាំបាច់តែពណ៌ឈុតៗជាមួយអាវដែលកាត់តម្រូវតាមកម្មវិធីនោះទេ។ លើសពីនោះគឺតែងរក្សាទុកឱ្យល្អដើម្បីប្រើនៅពេលក្រោយទៀត»។

ចំណែក អ្នកស្រី កែវ រីដា វ័យ ៣២ឆ្នាំជាបុគ្គលបម្រើការនៅក្រុមហ៊ុនមួយកន្លែងនៅភ្នំពេញបានឱ្យដឹងផងដែរថា ក្រណាត់ហូល ផាមួង សូត្រនេះ មិនមែនប្រើតែចំពោះស្រីៗនោះទេ បុរសក៏អាចប្រើបានដែរ។

អ្នកស្រី រីដាបន្តថា៖ «ការប្រើប្រាស់ហូល ផាមួង រឺ ក៏សូត្រនេះគឺមិនមែនតែស្រីទេ ប្រុសៗក៏គេនិយមដែរគឺកាត់ជាអាវចឹងទៅ គឺទាំងស្រីទាំងប្រុសពេលបានស្លៀកពាក់លើខ្លួនហើយ គឺស្អាតប្លែកតែម្តង។ ខ្ញុំ និងគ្រួសារតែងតែកាត់ជាគូ ដូចជាពណ៌ដូចគ្នាជាដើម ព្រោះសម័យនេះភាគច្រើនគេនិយមចឹង ជួនកាលជាសំពត់បត់ជួនកាលឱ្យជាងច្នៃម៉ូតជារ៉ូបក៏មាន»។

លោក កៃ សុគន្ធ វ័យ ២៨ឆ្នាំជាកូនជាងក្នុងហាងកាត់សម្លៀកបំពាក់បុរាណសម័យដែលមានឈ្មោះថា ស្នាដៃខ្មែរនៅម្តុំផ្សារថ្មីបានឱ្យដឹងថា៖ «រាល់ថ្ងៃរវល់ខ្លាំងជាមួយនឹងការកំម្ម៉ង់ម៉ូតរបស់ភ្ញៀវជាពិសេសក្នុងរដូវមង្គលការ គឺភាគច្រើនមកកាត់ទាំងស្រីទាំងប្រុស គឺជាបែបប្រពៃណី និងរ៉ូបសម័យ»។

ក្នុងមួយថ្ងៃក្នុងហាងដែលលោក សុគន្ធធ្វើការ គឺទទួលការបញ្ជាកាត់ពីភ្ញៀវមិនក្រោម៥កំប្លេរនោះទេ ហើយចំណែកការរកចំណូលវិញគឺគួរសមដែរក្នុងមួយខែៗ។

កៃ សុគុន្ធ បន្ថែមថា៖ «ខ្ញុំគិតថា បងប្អូនខ្មែរ គឺគាត់ចាប់អារម្មណ៍ និងសម្លៀកបំពាក់ប្រពៃណីច្រើនបើទោះបីជាគាត់កាត់ម៉ូតស៊ិចស៊ីបន្តិច តែក៏ពួកគាត់មិនបោះបង់ចោលក្រណាត់ហូលផាមួងខ្មែរ ជាពិសេសនៅពេលមានកម្មវិធីផ្សេងៗ ស្រីៗនិយមស្លៀកតែម្តង។ ក្នុងនាមខ្ញុំជាយុវជនខ្មែរម្នាក់មានអារម្មណ៍សប្បាយចិត្តនៅពេលដែលឃើញបងប្អូនខ្មែរនៅតែរក្សាបាននូវកេរដំណែលរបស់ខ្លួនដូចនេះ»។

ប្រទេសខ្មែរជាប្រទេសមួយដែលមានវប្បធម៌ប្រពៃណី ទំនៀមទំលាប់ដ៏ឧត្តុង្គឧត្តមមួយនៅអាស៊ីអាគ្នេយ៍ជាយូរលុងណាស់មកហើយ។ យ៉ាងណាមិញ តម្បាញគឺជាស្នាដៃសិល្បៈសិប្បកម្មខ្មែរមួយ ដែលមានតាំងពីក្រោយសម័យហ្វូណានឬនគរភ្នំ សំលៀកបំពាក់ប្រពៃណី ដែលធ្វើអំពីសូត្រដូចជាហូល ផាមួង ចរបាប់ សារុងសូត្រ។ល។ អាចប្រើប្រាស់បាន គ្រប់ជាន់ថ្នាក់ ទាំងប្រជារាស្ត្រទាំងនាម៉ឺនមន្ត្រីតូចធំរហូតដល់សែរាជវង្ស និងព្រះមហាក្សត្រ៕



# តើស្ថាប័នណាដឹងថា ការដ្ឋានសំណង់ទាំងអស់នៅកម្ពុជា ត្រូវការខ្សាច់និងឥដ្ឋប៉ុន្មានទេ?

*ដោយ៖ អរិយបុត្រ*

ដោយសារតែកំណើននៃវិស័យសំណង់ និងការអភិវឌ្ឍប្រទេសកើនឡើងដ៏គំហុក នៅក្នុងរយៈពេលប្រមាណជាមួយទស្សវត្សរ៍ចុងក្រោយនេះ បានធ្វើឲ្យសេចក្តីត្រូវការខ្សាច់ ថ្ម ឥដ្ឋ និង ស៊ីម៉ង់ ដែលជាធនធានផលិតនៅក្នុងស្រុកមានតម្រូវការកើនឡើងហួសប្រមាណ ជាពិសេសខ្សាច់ ។

រហូតមកដល់ពេលនេះ អ្នកនាំសារ នៅមិនទាន់អាចរកបាននូវតួរលេខពិតប្រាកដនៃតម្រូវការធនធានខ្សាច់ ថ្ម ស៊ីម៉ង់ និង ឥដ្ឋ សរុបនៅក្នុងមួយឆ្នាំៗ ដែលត្រូវហូរចូលទៅក្នុងដំណើរការអភិវឌ្ឍរបស់ប្រទេស នៅលើវិស័យសំណង់អាគារ និង ការអភិវឌ្ឍស្ពាន និង ផ្លូវនៅទូទាំងប្រទេសនៅឡើយទេ ខណៈដែលមន្ត្រីជំនាញបានបដិសេធថា មិនមានតួលេខ ឬ មិនបានបូកសរុប ឬ ជាប់ធុរៈនិយាយមិនទាន់បាន ប៉ុន្តែបើមើលទៅតាមទិដ្ឋភាពជាក់ស្តែងនៃការដ្ឋានសំណង់ទាំងនោះ គឺថា ធនធានធម្មជាតិ ដែលយកមកផ្គត់ផ្គង់វិស័យនេះ គឺមានទំហំមហាសាល ហើយកំពុងតែកើនឡើងច្រើនហើយច្រើនទៀត បើផ្អែកនៅលើកំណើនពីមួយឆ្នាំទៅមួយឆ្នាំ។

លោករិន ចេតនា ជាប្រជាពលរដ្ឋមួយរូបវ័យ៣៨ ឆ្នាំកំពុងតែសាងសង់ផ្ទះល្វែងត្រឹមតែ ២ជាន់ មួយរូបនៅម្តុំផ្លូវ វេងស្រេង បានអះអាងថា រហូតមកដល់ពេលនេះសំណង់ផ្ទះល្វែងដែលលោកកំពុងតែសាងសង់បានសម្រេច ប្រមាណជា ៨០ភាគរយ គឺបានប្រើប្រាស់ខ្សាច់តាមឡានត្រឹមតែ ១០គូបនោះ គឺមិនក្រោម២០ឡានទេ ហើយឥដ្ឋវិញ ស៊ីម៉ង់វិញក៏មិនតិចដែរ ចុះទម្រាំអគារធំៗ តើនៅក្នុងការដ្ឋានមួយ គេប្រើខ្សាច់ ថ្ម ស៊ីម៉ង់ និង ឥដ្ឋប៉ុន្មានទៅ ហើយតើយើងរាប់ចេញទេ បើឥឡូវនេះអគាធំៗខ្ពស់ៗរីកដូចផ្សិតពេញតែទីក្រុងទៅហើយនោះ ។

លោកបានបញ្ជាក់ថា ៖«ត្រឹមតែជាងឲ្យដឹកខ្សាច់នោះក៏ចង់វិលមុខរកធ្វើការរកស៊ីអីមិនចង់កើតដែរ ដោយសារវាត្រូវការតាំងពីខ្សាច់រៀបឥដ្ឋ ខ្សាច់រៀបការ៉ូ ខ្សាច់បូក ខ្សាច់ចាក់ក្រោមផ្ទះសព្វយ៉ាង»។

> **“នៅក្នុងមួយការ៉េ គឺត្រូវការឥដ្ឋប្រមាណ ៥៥ដុំ ខ្សាច់វិញ គឺប្រហែលជា ពី ៥ទៅ ៦ធុងស៊ៀគ្រូ ហើយ ស៊ីម៉ង់វិញ មួយបាវ គឺអាចលាយជាមួយនឹងខ្សាច់រៀបបានប្រហែលជា ១០ ទៅ ១២ការ៉េ”**

លោកបានបន្តឲ្យដឹងទៀតថា ដោយសារតែលោកចង់សង់ផ្ទះឲ្យមាំមួយសម្រាប់គ្រួសារស្នាក់នៅ មានសុវត្ថិភាព និងផាសុកភាព ដូច្នេះហើយ បានជាលោកត្រូវទិញសម្ភារខ្លួនឯងដោយជាងយកតែឈ្នួលសាងសង់ប៉ុណ្ណោះ ប៉ុន្តែលោកបានអះអាងថា លើកក្រោយ ប្រសិនបើលោកសាងសង់ទៀត សូមម៉ៅឲ្យគេទៅ ពីព្រោះវាវិលមុខនឹងការដើរទិញសម្ភារនេះតែម្តង។

លោក សេង ថេត ដែលជាប្រជាពលរដ្ឋកម្ពុជាមួយរូបទៀតដែលមានទីលំនៅនៅអរិយក្សត្របានឲ្យដឹងថា ដោយសារតែសំណង់វាច្រើនពេល តម្រូវការខ្សាច់គឺហាក់ដូចជាត្រូវការមិនចេះអស់មិនចេះហើយ ។ លោកបានបន្តថា នៅក្នុងដំណើរមកធ្វើការពីតំបន់អរិយក្សត្រមកភ្នំពេញរាល់ថ្ងៃ ពេលឆ្លងសាឡាង ពេលណាក៏ឃើញសកម្មភាពបូមខ្សាច់ ឬ ក៏នាវាដឹកខ្សាច់គេបូម ហើយដឹកដែរ។

លោកបានបញ្ជាក់ថា៖ «ពេលខ្លះខ្ញុំចេញពីធ្វើការ ម៉ោង ៨ ទៅ ៩ យប់ យើងឆ្លងសាឡាងនៅតែឃើញ នៅតែជួបកប៉ាល់ដឹកខ្សាច់ពេញៗតែរហូតមិនសូវខាននោះទេ»។

មន្ត្រីអ្នកនាំពាក្យក្រសួងរ៉ែ និងថាមពលមិនអាចទំនាក់ទំនងបាន នៅពេលអ្នកនាំសារ ប្រឹងប្រែងដើម្បីសុំការបំភ្លឺអំពីរឿងធនធានខ្សាច់នេះ ប៉ុន្តែគេដឹងថា ដើម្បីបំពេញសេចក្តីត្រូវការខ្សាច់យកមកបម្រើក្នុងការដ្ឋានសាងសង់នានាដែលកំពុងតែរីកដូចផ្សិតនាពេលបច្ចុប្បន្ននេះ នៅតាមស្ទឹងតាមទន្លេ ដែលមានលំហូរទឹក ដោយ

កន្លែងទាំងនោះគឺមានទាំងស្របច្បាប់ និង មិនស្របច្បាប់។

ការដ្ឋានបូមខ្សាច់គឺគេសង្កេតឃើញមានជាហូរហែរនៅតាមដងទន្លេមេគង្គ ហើយសូម្បីតែនៅរាជធានីភ្នំពេញក៏មានដែរ ហើយការដ្ឋានទាំងនោះបានដឹកខ្សាច់ទាំងកប៉ាល់យកមកចែកចាយតាមដេប៉ូខ្សាច់នៅទូទាំងប្រទេស ដោយនៅក្នុងនោះ សូម្បីតែខេត្តរតនគិរី ដែលជាខេត្តមួយនៅភូមិភាគឥសាន្តនៃប្រទេស ក៏មានកន្លែងបូមខ្សាច់ទាំងនោះដែរ។




ការដ្ឋានបូមខ្សាច់ខ្លះក្រសួងជំនាញមានទាំងក្រសួងធនធានទឹក និងឧត្តុនិយម និង ក្រសួងរ៉ែ និងថាមពល មិនអនុញ្ញាតឲ្យបូមខ្សាច់ឡើយ កន្លែងខ្លះគឺអាចបូមបាន ប៉ុន្តែជាទូទៅសម្រាប់ប្រជាពលរដ្ឋសាមញ្ញ គឺគ្មានអ្នកណាដឹងថា ការដ្ឋានទាំងនោះស្របច្បាប់ ឬ មិនស្របច្បាប់នោះទេ ខណៈដែលរបាយការណ៍ និងការចោទប្រកាន់អំពីផលប៉ះពាល់ដោយសារតែការបូមខ្សាច់ទាំងនេះ ដូចជាបាក់ច្រាំងទន្លេ បាក់ដី បាក់ភូមិករ ប្រជាពលរដ្ឋគឺកើតមានជាហូរហែ។

កន្លែងខ្លះទៅអាជ្ញាធរថា គ្មានច្បាប់ ហើយចុះមកបិទ ប៉ុន្តែនៅពេលដែលអាជ្ញាធរ ពិសេសក្រសួងជំនាញទៅបាត់គេមកបូមវិញដដែលក៏មាន។ ករណីដូចជា នៅការដ្ឋានបូមខ្សាច់នៅខេត្តរតនគិរី ដែលក្រសួងជំនាញថា គ្មានការដ្ឋានបូមខ្សាច់ណា មានច្បាប់ទេ ប៉ុន្តែគេឃើញសកម្មភាពបូមនិងធ្វើអាជីវកម្មខ្សាច់នេះមានជាហូរហែ ហើយចេះតែបូមដើម្បីផ្គត់ផ្គង់តម្រូវការជាបន្តបន្ទាប់។

នៅខេត្តតាកែវក៏មានការដ្ឋានបូមខ្សាច់ខ្លះដែរ ដោយទីតាំងទាំងនេះ គឺនៅតាមស្ទឹង ដោយមានការត្រូវគ្នារវាងអាជ្ញាធរមូលដ្ឋាន។ ដោយឡែកនៅតាមដងទន្លេមេគង្គ ក្រសួងរ៉ែ និងថាមពល ធ្លាប់បានដាក់ឲ្យមានការដ្ឋានបូមខ្សាច់ប្រមាណជា ៩កន្លែងនៅតាមដងទន្លេមេគង្គ ដោយការដ្ឋានទាំងនោះ គឺត្រូវបានដាក់ឲ្យបូមធ្វើអាជីវកម្មក្នុងគោលបំណងស្តារផ្លូវនាវាចរណ៍ តាមដងទន្លេដែលទីតាំងទាំងនោះមានដូចជាស្ថិតនៅស្រុកកងមាស ខេត្តកំពង់ចាម, ស្រុកមុខកំពូល និងស្រុកខ្សាច់កណ្តាល ខេត្តកណ្តាលជាដើម ប៉ុន្តែគេដឹងថា កន្លែងបូមគឺមានលើសពីនេះ ច្រើនកន្លែងទៀត ហើយក៏គេមិនដឹងថា អាខុសច្បាប់មានប៉ុន្មានកន្លែងនោះទេ។

លោក ឱត ទីណា រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យ ក្រសួងរ៉ែ និងថាមពល មិនអាចទំនាក់ទំនងបានឡើយនៅពេលដែលអ្នកនាំសារស្នើសុំការបំភ្លឺរឿងតម្រូវការខ្សាច់នេះ។

ដោយសារតែលំបាកនៅក្នុងការស្វែងរកតួលេខនៃតម្រូវការនូវធនធានធម្មជាតិយកមកបំពេញសេចក្តីត្រូវការផ្នែកសំណង់នេះ ដូចជា ខ្សាច់ ស៊ីម៉ង់ ឥដ្ឋ វាពិបាកពីក្រសួងជំនាញ ជាពិសេសដូចជាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់,និង ក្រសួងរ៉ែនិង ថាមពលជាដើមនោះអ្នកនាំសារបានជួបជាមួយនឹងវិស្វករនៃក្រុមហ៊ុនដែលកំពុងតែសាងសង់នៅការដ្ឋានមួយនៅតាមបណ្តោយផ្លូវជាតិលេខ ១ មួយកន្លែងបានឲ្យដឹងថា រឿងស៊ីម៉ង់មិនជាបញ្ហានោះទេ ហើយនៅពេលនេះ យើងដឹងថា ឥឡូវនេះ ខ្មែរយើងមានរោងចក្រស៊ីម៉ង់ច្រើន ហើយនៅមានធនធានថ្មកំបោរអាចធ្វើស៊ីម៉ង់នេះច្រើនកន្លែង ណាមួយយើងទើបតែផលិតចឹងវានៅមាន សក្តានុពលនិងប្រើប្រាស់បានយូរឆ្នាំទៀត ប៉ុន្តែឥដ្ឋដូចជាពិបាកបន្តិចដោយឥឡូវនេះ ដីឥដ្ឋគឺ ដូចជាខ្វះត់ ពេលខ្លះក្រុមហ៊ុនបញ្ជាទិញឥដ្ឋដល់ពេលខ្លះដាច់ស្តុក ដោយខាងឡូឥដ្ឋប្រាប់ថា ពិបាករកដីឥដ្ឋ។

វិស្វករសុំមិនបញ្ចេញអត្តសញ្ញាណដដែលបានឲ្យដឹងថា ពេលខ្លះសូម្បីតែឥដ្ឋយកមកពីវៀតណាម ដែលមិនសូវមានគុណភាពក៏អស់ស្តុកដែរ ដូច្នេះជាដំណោះស្រាយក្រុមហ៊ុនប្រើប្រាស់ឥដ្ឋធ្វើពីស៊ីម៉ង់តែម្តង។

វិស្វកររូបនោះបានឲ្យដឹងថា ដើម្បីឲ្យដឹងថា តើសំណង់នីមួយៗអាចប្រើប្រាស់ធនធានខ្សាច់ ស៊ីម៉ង់ និង ឥដ្ឋនោះអស់ប៉ុន្មានគឺអាចដឹងបាន ប្រសិនបើគេដឹងទំហំអគារ កំពស់អគារ ហើយគុណទៅ។

លោកបានបញ្ជាក់ថា « ទោះបីជាមិនបានត្រឹមត្រូវ ១០០ ភាគរយ ប៉ុន្តែគេអាចដឹង និងប៉ាន់ប្រមាណនៃតម្រូវការធនធានទាំងនោះបានតាមរូបមន្ត ដោយគេដឹងថា នៅក្នុងមួយការ៉េ គឺត្រូវការឥដ្ឋប្រមាណ ៥៥ដុំ ខ្សាច់វិញ គឺប្រហែលជា ពី ៥ទៅ ៦ ធុងស្ប៉ៃត្រូ ហើយ ស៊ីម៉ង់វិញ មួយបាវ គឺអាចលាយជាមួយនឹងខ្សាច់រៀបបាន ប្រហែលជា ១០ ទៅ ១២ការ៉េ»។

វិស្វករវ័យក្មេងរូបនោះ បាននិយាយលេងសើច មកកាន់អ្នកសារព័ត៌មានយើងថា បើពិបាករកតួលេខពេក បងឯ (អ្នកយកព័ត៌មានអ្នកនាំសារ)អាចដើរវាស់តាមអគារទៅដឹងហើយ។

តាមតួរលេខពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់បានឲ្យដឹងថា នៅក្នុងឆមាសទីមួយនៃឆ្នាំ ២០១៩ នេះ ទុនវិនិយោគក្នុងវិស័យសំណង់បានកើនដល់ទឹកប្រាក់ជាង៣០០០លានដុល្លាអាមេរិកពោលគឺមានការកើនឡើង ៥៧,៧៥ភាគរយធៀបរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

ប្រភពដដែលបានឲ្យដឹងថា ទំហំទុនវិនិយោគសរុបក្នុងរយៈពេល៦ខែឆ្នាំនេះមាន គម្រោងចំនួន២.០៤៧ និងស្ថិតនៅលើទំហំផ្ទៃដីប្រមាណ៧លានម៉ែត្រការ៉េ ដែលក្នុងនោះគម្រោងសាងសង់ចំនួន១៥៤ ស្មើនឹងទឹកប្រាក់វិនិយោគប្រមាណ៣,០៧ ពាន់លានដុល្លារ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង។ ដោយឡែកគម្រោងចំនួន១.៨៩៣ ស្មើនឹងទំហំទឹកប្រាក់វិនិយោគប្រមាណ៣១៨លានដុល្លារ ស្ថិតនៅក្រោមការគ្រប់គ្រងថ្នាក់ក្រោមជាតិ ដែលរួមមានរដ្ឋបាលខេត្ត-ក្រុង ជាសេនាធិកាទទួលបន្ទុក។

ប្រភពដដែលបានបន្តថា បច្ចុប្បន្ននេះអាគារសំណង់ដែលមានកម្ពស់ចាប់ពី៩ជាន់ឡើងទៅនៅទូទាំងប្រទេស មានចំនួន១.៣២៩ អាគារ ហើយសំណង់លំនៅដ្ឋានបែបបុរីមានចំនួន ២៥៨ទីតាំង ដោយមិនរាប់បញ្ចូលសំណង់លំនៅដ្ឋានរាយប៉ាយនៅតាមតំបន់នោះទេ៕



*ខ្សាច់ និងថ្មគ្រួសសំណង់កំពុងមានតម្រូវការខ្ពស់ ខណៈការអភិវឌ្ឍវិស័យសំណង់កំពុងមានកំណើនខ្ពស់។ រូបភាពៈ សហការី*



*សកម្មភាពបូមខ្សាច់សមុទ្រចាក់បំពេញតម្រូវការ។ រូបភាពៈ សហការី*

# សិប្បកម្មស្វាយចន្ទី កំពុងប្រឹងទាក់ទាញទីផ្សារ



សិប្បកម្មផលិតផលគ្រាប់ស្វាយចន្ទី ជាលក្ខណៈគ្រួសារមួយនៅស្រុកស្វាយលើ ខេត្តកំពង់ចាម បានបង្កើតឡើងរយៈពេលជិត១០ឆ្នាំមកហើយ លើផ្ទៃដីប្រមាណ៣ហិចតា ដែលអាចរកចំណូលបានច្រើនគួរសមក្នុងមួយរដូវកាល។ ម្ចាស់សិប្បកម្មផលិតគ្រាប់ស្វាយចន្ទីតាមបែបធម្មជាតិបានឲ្យដឹងថា ក្នុងផ្ទៃដីខាងលើនេះ គាត់អាចទទួលផលពីដើមស្វាយចន្ទីបានគ្រាប់ស្រស់ប្រហែលជាងមួយតោន។ គ្រាប់ស្រស់អាចលក់បានតម្លៃពី៦០០០រៀល ទៅ៧០០០រៀលក្នុងមួយគីឡូក្រាម។ បច្ចុប្បន្ននេះ សិប្បកម្មមួយនេះកំពុងតែធ្វើទំនើបកម្មនៃសិប្បកម្មរបស់ខ្លួន ដើម្បីចូលរួមប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិ។

*ដោយ៖ ផល សុផានិត*

ផលិតផលគ្រាប់ស្វាយចន្ទីធម្មជាតិ នៅក្នុងស្រុកស្វាយលើ ខេត្តកំពង់ចាម គឺជាផលិតផលកសិឧស្សាហកម្មមួយ នៅក្នុងចំណោមផលិតផលកសិឧស្សាហកម្មដទៃទៀតរបស់ខេត្តជាប់ដីសណ្តកទន្លេមេគង្គ ដែលសម្បូរដោយជីវជាតិ ហើយប្រជាពលរដ្ឋភាគច្រើនជាអ្នកស្រែចម្ការ។

សិប្បកម្មស្វាយចន្ទីចម្ការលើ ជាស្លាកសញ្ញានៃផលិតផលវេចខ្ចប់ហើយរបស់លោកឡឹង គឹមសាន ជាម្ចាស់សិប្បកម្មមួយនេះ។ លោកបានឲ្យដឹងថា ផលិតផលរបស់លោកបានដាក់លក់ក្នុងផ្សារទំនើបនានា និងនៅលើទីតាំងផ្ទាល់ក្នុងខេត្តកំពង់ចាម។

លោក ឡឹង គឹមសាន ឲ្យដឹងទៀតថា៖ «បាទនេះ ជាគ្រាប់ស្វាយចន្ទីតាមបែបធម្មជាតិ សម្ងួតពី៦០ ទៅ៨០ អង្សាសេ ហើយសំណើមរបស់គ្រាប់ស្វាយចន្ទីនៅសល់តែ១០ភាគរយ ខ្ញុំយកទៅលីងក្នុងឡ»។

សិប្បកម្មរបស់លោកឡឹង គឹមសាន មានកម្មករតែ៣នាក់ទេ ក្រៅពីនេះសុទ្ធសឹងតែជាកូនក្មួយរបស់ម្ចាស់សិប្បកម្មខាងលើ ដែលមកជួយម្តងម្កាលតែប៉ុណ្ណោះនៅពេលដែលពួកគេទំនេរពីការសិក្សា។ អ្វីដែលធ្វើឲ្យចាប់អារម្មណ៍ទៀតនោះ គឺសិប្បកម្មខាងលើ មិនទិញគ្រាប់ស្វាយចន្ទីពីខាងក្រៅមកទេ ព្រោះខ្លាចគ្រាប់ស្វាយចន្ទីទាំងនោះមានជាតិគីមី ដែលសិប្បកម្មខាងលើត្រូវការតែគ្រាប់ស្វាយចន្ទីសុទ្ធពីធម្មជាតិតែប៉ុណ្ណោះ។

អ្នកនាង សុខ ធីតា ជាកម្មករក្នុងសិប្បកម្មបាននិយាយថា គ្រាប់ស្វាយចន្ទីមិនមែនងាយស្រួលធ្វើទេ ព្រោះត្រូវដឹងអំពីបច្ចេកទេសធ្វើទើបទទួលបានគ្រាប់ស្អាត ហើយលក់បានតម្លៃថ្លៃ។ ធីតា៖ «គាបម្តងបាន៥គីឡូ។ ចាស! ពិបាកបើចន្ទីមិនជាប់សម្បកទេ ពេលពុះវាមកវាចេញសាច់គ្រាប់តែម្តង តែបើយើងគាបវាខ្លះនោះ វាបែកសាច់យើងដាក់វាម្តុំដោយឡែក មិនលាយចូលរបស់ល្អទេ»។

លោកឡឹង គឹមសាន មានដីចម្ការស្វាយចន្ទីចំនួន៣ហិចតា ដែលអាចផ្តល់ផលគ្រាប់ក្នុងមួយ



រដូវកាលចំនួនជាង១តោនកន្លះ។ ក្រៅពីនោះគាត់បានប្រមូលទិញពីម្ចាស់ចម្ការផ្សេងទៀតដែលមាននៅក្នុងភូមិ ដើម្បីយកមកកែច្នៃជាផលិតផលសម្រេច រួចវេចខ្ចប់ជាកញ្ចប់ៗទៅតាមប្រភេទនិងតម្លៃ។

កញ្ញា កឿយ ស៊ីដេត ជាកម្មករវិចខ្ចប់ឲ្យដឹងថា៖ «ចាស់! ពេលដែលលីងស្ងួតហើយ យើងរើសយកវាដាក់ចូលក្នុងថង់តម្លៃ ៥០០០ ឬក៏ ១០០០០រៀល ចំណែករបស់ល្អបំផុត មានតម្លៃចាប់ពី២០០០០ ដល់២៥០០០រៀល»។

លោកឡឹងគឹមសានបានបន្ថែមថាតាមធម្មតា លោកចាប់ផ្តើមវិចខ្ចប់ជាកញ្ចប់នេះ តិចៗទេ ដែលក្នុងមួយថ្ងៃសិប្បកម្មរបស់គាត់អាចវិចបានពី៥០ ទៅ១០០កញ្ចប់។ លោកមានបំណងចង់ពង្រីកការងារនេះ ដោយមានទាំងការបណ្តុះកូនរហូតដល់ទទួលបានគ្រាប់ចន្ទីឆ្អិន និងវេចខ្ចប់។

លោកគឹមសានឲ្យដឹងថា ដើមស្វាយចន្ទីត្រូវដាំរយៈពេល៣ឆ្នាំទើបទទួលបានផ្លែ។ បញ្ហាប្រឈមរបស់គាត់ គឺបច្ចេកទេសដាំស្វាយចន្ទីឲ្យបានផលច្រើន បច្ចេកទេសសម្ងួតគ្រាប់ និងការគាំទ្រផលិតផលខ្មែរ ពីប្រជាពលរដ្ឋ។

ក្នុងពេលកន្លងមក មន្ទីរពាណិជ្ជកម្មខេត្តបានជួយបណ្តុះបណ្តាលជំនាញទាក់ទងនឹង



*ផលិតផលគ្រាប់ស្វាយចន្ទី។ រូបភាព៖ សហការី*

ការផ្សព្វផ្សាយផលិតផល និងការកែច្នៃសម្រាប់សម្រួលដល់ការនាំផលិតផលចេញទៅក្រៅប្រទេស ការកែច្នៃគ្រាប់ស្វាយចន្ទីឲ្យត្រូវតាមស្តង់ដារអន្តរជាតិជាដើម។

ប្រភពពីក្រសួងពាណិជ្ជកម្មបានបង្ហាញថា ផលិតផលគ្រាប់ស្វាយចន្ទី មិនទាន់ត្រូវបានបង្កើតសមាគមន៍ និងមិនទាន់អាចចាត់ជាទំនិញសម្គាល់ភូមិសាស្ត្រសម្រាប់នាំចេញនៅឡើយ និងដោយសារតែផ្ទៃដីដាំដុះស្វាយចន្ទីនៅមានកម្រិតតិចតួចនៅក្នុងប្រទេស។

លោកឡឹង គឹមសានបានបញ្ជាក់ថា៖ «ខ្ញុំនឹងខិតខំធ្វើវាឲ្យកាន់តែមានអនាម័យ ដែលនឹងធ្វើឲ្យអន្តរជាតិទទួលស្គាល់ផលិតផលរបស់ខ្មែរយើង ដែលយើងអាចធ្វើបាន»។

ម្ចាស់សិប្បកម្មគ្រាប់ស្វាយចន្ទីចម្ការលើ បន្តថា ការវេចខ្ចប់គឺសំខាន់ណាស់ ដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់អតិថិជន។

លោកបានរៀបរាប់ថា៖ «កាលពីដំបូងខ្ញុំគ្រាន់តែវិចខ្ចប់ដាក់ថង់ធម្មតា បើយើងលក់ចេញទៅក្រៅប្រទេស ឬផ្សារទំនើបនោះគឺលក់មិនចេញទេ។ សព្វថ្ងៃនេះគឺមានការខុសគ្នាច្រើនដោយប្រើការវិចខ្ចប់តាមបែបស្តង់ដារនេះ»។

លោក ឡឹង គឹមសាន បន្តថា សម្រាប់ថង់វិចខ្ចប់សព្វថ្ងៃ គឺទិញពីផ្សារ ហើយត្រូវអ៊ុតមាត់ថង់។ លោកទទួលស្គាល់ថា កញ្ចប់ផលិតផលរបស់លោកមិនមានលក្ខណៈទំនើបនៅឡើយទេ ប៉ុន្តែអតិថិជនគេទទួលស្គាល់ផលិតផលរបស់គាត់បណ្តើរៗហើយ។

បច្ចុប្បន្ននេះ វិស័យកសិឧស្សាហកម្មមិនទាន់មានបង្កើតជាសហគមន៍ ឬសមាគមនៅឡើយទេ នេះបើតាមប្រសាសន៍របស់ម្ចាស់សិប្បកម្ម។ លោកឲ្យដឹងថា ព្រោះតែបច្ចុប្បន្នក្នុងខេត្តកំពង់ចាមមិនទាន់មានសមាគមណាមួយបង្កើតឡើងទាក់ទងនឹងផលិតផលគ្រាប់ស្វាយចន្ទី តែគាត់តែងតែដាក់តាំងពិពណ៌នៅតាមស្តង់របស់មន្ទីរ ពាណិជ្ជកម្ម ឬក្រសួងពាណិជ្ជកម្ម ដើម្បីឲ្យប្រជាជនកាន់តែស្គាល់ផលិតផលរបស់គាត់។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញវិធានការមួយចំនួន ដើម្បីសម្រួលដល់ផលិតកម្មដំណាំស្វាយចន្ទី ដែលកំពុងមានតម្រូវការពីទីផ្សារអន្តរជាតិ។ នេះបើយោងតាមសេចក្តីណែនាំរបស់លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម ដែលបានចេញផ្សាយកាលពីពេលថ្មីៗនេះ។

ថ្មីៗនេះ រដ្ឋាភិបាលបានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាជាមួយ «សមាគមស្វាយចន្ទីវៀតណាម ស្តីពីការជំរុញផលិតកម្មស្វាយចន្ទីកម្ពុជាសម្រាប់ការនាំចេញ»។ ទន្ទឹមនឹងនេះ ភាគីសមាគមស្វាយចន្ទីវៀតណាម បានយល់ព្រមផ្តល់ប្រភេទពូជស្វាយចន្ទី គាំទ្របច្ចេកទេសនិងប្រមូលទិញផលិតផលស្វាយចន្ទីពីកសិករ ឬសហគមន៍កសិកម្ម ដោយអនុវត្តតាមគោលការណ៍ផលិតកម្មកសិកម្មតាមកិច្ចសន្យា៕

# ការដាំដំណាំលើទឹក
## ហាក់ចាប់អារម្មណ៍ពីកសិករសម័យថ្មី

*ដោយៈ ផល សុផានិត*



កសិករកំពុងចាប់អារម្មណ៍នឹងបច្ចេកទេសការដាំដំណាំលើទឹក។

បច្ចេកវិទ្យានៃការដាំដំណាំនៅលើទឹក ឬដំណាំមិនប្រើដី ដែលគេហៅជាភាសាបរទេសថា Hydroponic ដែលអ្នកជំនាញផ្នែកកសិកម្មនៅក្នុងបណ្ដាប្រទេសជឿនលឿនមួយចំនួនបានរកឃើញនោះ បច្ចុប្បន្នកសិកម្មសម័យទំនើបក្នុងប្រទេសកម្ពុជាហាក់មានការពេញនិយមដាំ ក៏កំពុងតែទទួលបានភាពជោគជ័យលើការដាំជាបន្តបន្ទាប់។

ម្ចាស់ចម្ការដាំដំណាំនៅលើទឹកស្ថិតនៅជាយក្រុងភ្នំពេញ លោក កុយ វ៉ាន់ និយាយថា ការដាំដំណាំមិនប្រើដី ដំបូងឡើយគាត់ជួបប្រទះនឹងហានិភ័យខ្លះដែរ តែឥលូវគ្មានបញ្ហាច្រើនដូចកាលពីមុននោះទេ។ លោកបន្ថែមថា កត្តាសំខាន់បំផុតនោះ គឺត្រូវយល់ដឹងអំពីរបៀបរៀបចំដាំនិងការថែទាំលើប្រព័ន្ធគ្រប់គ្រងទឹក។





*កត្តាសំខាន់បំផុតនោះ គឺត្រូវយល់ដឹងអំពីរបៀបរៀបចំដាំនិងការថែទាំលើប្រព័ន្ធគ្រប់គ្រងទឹក។ រូបភាពៈ ផល សុផានិត*

លោកកុយ វ៉ាន់បានចាប់ផ្ដើមរបរនេះជាច្រើនឆ្នាំមកហើយដែរ ហើយរហូតមកដល់ពេលនេះ គាត់បានទទួលផលចំណេញគួរសម។ លោកបានឲ្យដឹងថា បើគិតអំពីប្រាក់ចំណេញក្នុងពេលភ្លាមៗនោះគឺមិនបានទេ ដោយសារតែ សម្ភារ និងឧបករណ៍ប្រើប្រាស់របស់ប្រព័ន្ធហៃដ្រូផូនិចនេះមានតម្លៃថ្លៃ។

កសិដ្ឋានរបស់លោក កុយវ៉ាន់បានចំណាយប្រាក់ជាងពាន់ដុល្លារអាមេរិក ដើម្បីតម្លើង និងរៀបចំរោងបន្លែតាមបែបបច្ចេកទេសហៃដ្រូផូនិកនេះនៅលើដីប្រមាណជា៦០០ម៉ែតការ៉េ។

លោកបន្តថា ដំណាំលើទឹកនេះមិនចាំបាច់ថែទាំច្រើននោះទេ រីឯកម្លាំងពលកម្មក៏ចំណាយតិចទៅតាមនោះដែរ គឺមិនចាំបាច់បោចស្មៅ និងរកកម្មករថែទាំ។ លោកកុយ វ៉ាន់ ឲ្យដឹងថា ក្នុងដីរបស់លោកតែ៦០០ ម៉ែត្រការ៉េ អាចរកកម្រៃបានជិត៩លានរៀល អ្វីដែលសំខាន់គាត់អាចដាំដុះបាន១២ខែពេញក្នុងមួយឆ្នាំ។

លោក កុយ វ៉ាន់ ថា៖ «ពីដំបូងគឺយើងគិតថាការដាំនៅលើ ហាយដ្រូប៉ូនិច ចំនាយទុនច្រើន ប៉ុន្តែបើយើងគិតទៅលើរយៈពេលនៃការដាំវិញ រយៈពេលយូរឆ្នាំ គឺអាចចំណាយទុនទាបជាងការដាំនៅលើដី។ ដោយសារទី១ គឺអាចដកពីតំលៃពលកម្មម្ដងតិចៗនោះ យើងទៅគិតវិញនោះ វាជាកត្តាមួយដ៏សំខាន់នៃការចំណេញ ហើយមួយវិញទៀតគឺដីយើងមានទំហំតូចយើងអាចដាំបានច្រើន ដែលដីជិត៦០០ម៉ែត្រការ៉េ យើងទទួលផលក្នុង១វគ្គបានជិត១ពាន់ដុល្លារវិញ»។

លោកកុយ វ៉ាន់បន្ថែមទៀតថា រយៈពេលនៃការដាំដំណាំនេះ គឺទៅតាមប្រភេទនៃបន្លែ ប៉ុន្តែជាទូទៅគឺរយៈពេល៤០-៤៥ថ្ងៃ ចំពោះពពួកស្ពៃនិងសាឡាត់។ ក្នុងកសិដ្ឋានរបស់លោកគឺមានដាំតែសាឡាត់បរទេស ស្ពៃក្រញាញ់ និងស្ពៃខ្មៅ។

លោក សៀង សីហា ជាអ្នកស្រុករស់នៅក្នុងខេត្តតាកែវ បច្ចុប្បន្នបានបញ្ជាក់ថា លោកមានការចាប់អារម្មណ៍ជាខ្លាំងលើការដាំដំណាំប្រភេទនេះ ព្រោះជាបច្ចេកទេសទំនើបក្នុងការដាំដុះ មានសុវត្ថិភាពក្នុងការបរិភោគ ហើយពេលនេះលោកកំពុងតែរៀនសិក្សាអំពីវានិងសាកសួរពត៌មានមួយចំនួនពីអ្នកធ្លាប់មានបទពិសោធ ដើម្បីដាំដុះដោយខ្លួនឯងផង និងផ្សព្វផ្សាយបន្តទៀតផង។

លោក សៀង សីហា និយាយថា «វាជាបច្ចេកវិទ្យាថ្មី ដែលយើងមានទំហំដីតិចតែវាអាចដាំបានច្រើន និងចំណេញផលបានខ្លាំង»។

ភាគច្រើនប្រជាកសិករជ្រើសរើសពូជមកពីសហរដ្ឋអាមេរិច ព្រោះវាហាក់មានទីផ្សារខ្លាំងក្នុងរាជធានីភ្នំពេញ។ ដោយឡែកសម្រាប់អ្នករស់នៅជនបទស្រុកស្រែចម្ការនៅពុំទាន់មានការចាប់អារម្មណ៍នៅឡើយនោះទេតែបើដំណាំស្ពៃដែលដាំធម្មតានៅលើដីទើបមានការចាប់អារម្មណ៍។

លោក កុយ វ៉ាន់ បានប្រៀបធៀបទៅនឹងការដាំបន្លែនៅលើដីវិញ ខុសគ្នាខ្លាំងពីដំណាំនៅលើទឹក ដោយបានបញ្ជាក់ថា ការដាំនៅលើដី យើងអាចដាំបានតែ២ទៅ៣ដងតែប៉ុណ្ណោះក្នុង១ឆ្នាំ។ នេះគឺ ដោយសារតែការខាតបង់ពេលក្នុងការភ្ជួររាស់ដី ហាលដីឲ្យស្ងួត និងរវល់ច្រើនជាមួយការថែទាំ។ ដោយឡែក ការដាំនៅលើទឹកវិញ ពេលដកភ្លាម គឺអាចដាំភ្លាមៗតែម្ដង ដោយសារតែយើងបានការបម្រុងទុកកូនជាស្រេច។

និយាយអំពីទីផ្សារនិងចំណូលចិត្តរបស់អ្នកបរិភោគ លោកកុយ វ៉ាន់ បន្តថា ជាទូទៅបន្លែដែលពួកគាត់ដាំគឺជាបន្លែបរទេស ដែលមិនសូវចាប់អារម្មណ៍ពីប្រជាជនខ្មែរប៉ុន្មានទេ ជាពិសេសគឺតាមទីជនបទ។ ប៉ុន្តែបើនិយាយអំពីតម្លៃនៃបន្លែលើទឹកនេះ គឺខ្ពស់ជាងបន្លែដាំនៅលើដី។

លោកកុយវ៉ាន់៖ «សម្រាប់សាឡាត់ ពេលនេះមិនទាន់មានការពេញនិយមទេ នៅតាមបណ្ដាខេត្តមួយចំនួន ដូចជាខេត្តបាត់ដំបង គ្មានទីផ្សារលក់ដែរ មានតែនៅរាជធានីភ្នំពេញទេ សម្រាប់ពពួកសាឡាត់បរទេស។ តែសម្រាប់សាឡាត់ខ្មែរយើងធម្មតា ដែលយើងដាំនៅលើដីធម្មតា គឺមានទីផ្សារគ្រប់គ្រាន់ សម្រាប់តំលៃក៏វាមិនទាន់ប្រសើរនៅឡើយនោះដែរ។ នៅពេលដែលដំណាំនៅលើដីវាកើតច្រើន វាអាចធ្វើឲ្យដំណាំយើងទាបបន្តិចដែរ»។

សម្រាប់លោក សីហាមានបំណងចង់ឲ្យប្រជាពលរដ្ឋទូទៅ ជួយគាំទ្របន្លែសុវត្ថិភាព និងដើម្បីសុខភាពសាធារណៈ និងចៀសឲ្យផុតពីជំងឺផ្សេងៗ ដែលបង្កឡើងដោយសារធាតុគីមីនៅលើបន្លែដែលកំពុងនាំចូលពីប្រទេសជិតខាង។

លោក កុយ វ៉ាន់ បានបង្ហាញទស្សនៈមួយថា គាត់មិនចង់ចេះតែម្នាក់ឯងនោះទេ គឺគាត់ចង់បង្ហាញពីជំនាញបច្ចេកទេស ដែលគាត់មានជូនដល់ប្រជាកសិករ ដែលមានចំណាប់អារម្មណ៍ ដើម្បីជួយឲ្យប្រជាកសិករទូទៅផ្សេងៗទៀតអាចរកចំណូលបានតាមរយៈការដាំបន្លែនៅលើទឹក ឬដំណាំមិនប្រើដីនេះ ក្នុងការរួមចំណែកនៃការកាត់បន្ថយនៃភាពក្រីក្រ៕



*កូនដំណាំបន្លែលើទឹក ដែលត្រូវដាំដុះដោយប្រើប្រាស់ប្រព័ន្ធទឹក។ រូបភាពៈ បញ្ញា*



*ថ្នាលបណ្ដុះកូនដំណាំលើទឹក។ រូបភាពៈ បញ្ញា*

# យុវវ័យយល់ថា អាហារតាមអនឡាញ មានភាពស៊ីវិល័យ




**សម័យបច្ចេកវិទ្យា គ្រាន់តែអូសនៅលើទូរសព្ទដៃ អាចបញ្ជាទិញអាហារ ឬភេសជ្ជៈតាមតម្រូវការរបស់ខ្លួន ដែលធ្វើឲ្យយុវជនសម័យនេះចាប់អារម្មណ៍កាន់តែច្រើនឡើងៗ ជាពិសេសចំពោះអ្នកដែលគ្មានពេលវេលាគ្រប់គ្រាន់ ដើម្បីស្វែងរកទិញអាហារនៅខាងក្រៅ ឬចំអិនដោយខ្លួនឯង។ នៅក្នុងទីក្រុងភ្នំពេញ សេវាកម្មដឹកជញ្ជូនអាហារទៅដល់ទីតាំងអតិថិជនមានកាន់តែច្រើនឡើង ហើយជម្រើសរបស់អតិថិជនក៏កាន់តែសម្បូរបែប។**

*ដោយ៖ ផល សុផានិត*

សព្វថ្ងៃនេះអ្នករវល់នឹងការងារគ្មានពេលវេលាទៅទទួលទាននៅខាងក្រៅ ឬគ្មានពេលវេលាដើម្បីធ្វើម្ហូបអាហារញ៉ាំនៅផ្ទះមិនមែនជាបញ្ហាទៀតទេ។

សព្វថ្ងៃនេះ កម្ពុជាមានអ្នកបម្រើសេវាកម្មដឹកជញ្ជូន បញ្ជាទិញអាហារ ឬភេសជ្ជៈ តាមប្រព័ន្ធបច្ចេកវិទ្យា អែប (App / Application) ដើម្បីបំពេញតម្រូវការ ស្របតាមបរិបទនៃសម័យបច្ចេកវិទ្យា។

យុវជនមួយចំនួនបានយល់ឃើញថា ដើម្បីឲ្យទាន់សភាពការណ៍បច្ចុប្បន្ន និងដើរតាមបច្ចេកទេសទំនើប ហើយស៊ីវិល័យផងនោះ ភាគច្រើនពួកគាត់ប្រើប្រាស់ប្រព័ន្ធទំនើបនេះ។

លោក ឡុង វិចិត្រ ជាបុគ្គលិកបម្រើការងារនៅហាងកាហ្វេមួយកន្លែងក្នុងរាជធានីភ្នំពេញបាននិយាយថា ការបញ្ជាទិញអាហារតាមអនឡាញ មានភាពងាយស្រួល ដែលយុវវ័យនិយមប្រើនេៗ។ យើងងាយស្រួលមិនបាច់ដើរទៅទិញអាហារ ព្រោះយុវវ័យបច្ចុប្បន្ននេះរវល់ច្រើនក្នុងការធ្វើការងារប្រចាំថ្ងៃ ការងារសាលា និងកិច្ចការផ្សេងៗទៀត។

ឡុង វិចិត្រ បានបញ្ជាក់ថា៖ «តែអ្វីដែលសំខាន់នោះគឺយើងទិញអាហារតាមអនឡាញ មានភាពស៊ីវិល័យ»។ លោក បន្តថា លោកនិងមិត្តភក្តិមានការពេញចិត្តបញ្ជាទិញអាហារតាមសេវាកម្មថ្មីនេះ ប្រសិនបើប្រៀបធៀបរវាង ហាងអាហារ យើងចំណាយតិចជាងពី៣០ ទៅ៤០ភាគរយ នៃការទៅទទួលទានអាហារខាងក្រៅ។

ចំណែក កញ្ញា សេង ស៊ីនួន ជាបុគ្គលិករបស់សាខាពន្ធដាខេត្តរតនគិរី ដែលយូរៗម្តងបានមកភ្នំពេញ ក៏ប្រើប្រាស់សេវាកម្មនេះដែរ។ នាងបានឲ្យដឹងថា៖ «ការទិញអាហារតាមបែបថ្មីនេះ ងាយស្រួលជាងការទៅញ៉ាំអាហារនៅខាងក្រៅ ដោយសារតែនៅពេលនេះ អែប អាហារភាគច្រើនកំពុងតែបញ្ចុះតម្លៃ វាធ្វើឲ្យយើងចំណេញច្រើន»។

យុវតីរូបនេះ បន្តទៀតថា នៅក្នុងអែប អាចឲ្យយើងជ្រើសរើសម្ហូប ឬអាហារ តាមចំណង់ចំណូលចិត្ត និងមានហាងជាច្រើនដែលប្រព័ន្ធទំនើប (system) បញ្ចូលទៅក្នុងអែប។

នៅក្នុងទីក្រុងភ្នំពេញមានអ្នកបង្កើត App និងផេក ហ្វេសប៊ុក កើនឡើងច្រើន ហើយមួយនៅក្នុងចំណោមអ្នកទាំងនោះ មានលោក តុង ស៊ីវអាន ជាស្ថាបនិកក្រុមហ៊ុន និងជាអ្នកបង្កើត ហ្វូតអែប (Food App) សម្រាប់ដឹកជញ្ជូន ដល់ទីតាំងអតិថិជនបានបញ្ជាក់ថា ជាមួយនឹងភាពស៊ីវិល័យនៃប្រព័ន្ធបច្ចេកវិទ្យា ប្រជាជនកម្ពុជាកំពុងចាប់អារម្មណ៍បញ្ជាទិញម្ហូបអាហារតាមប្រព័ន្ធទំនើបមួយនេះ។

> **“នៅក្នុងអែប អាចឲ្យយើងជ្រើសរើសម្ហូប ឬអាហារ តាមចំណង់ចំណូលចិត្ត និងមានហាងជាច្រើនដែលប្រព័ន្ធទំនើបបញ្ចូលទៅក្នុងអែប...”**

លោក តុង ស៊ីវអាន«មូលហេតុដែលខ្ញុំបង្កើត ហ្វូតអែប នេះឡើងដោយសារតែយើងសំលឹងឃើញថា ប្រទេសកម្ពុជាយើងសព្វថ្ងៃគឺមានការរីកចម្រើនខាងជីវភាពរស់នៅ ណាមួយចរាចរណ៍នៅតាមផ្លូវមានការកកស្ទះខ្លាំង ដូច្នេះធ្វើឲ្យប្រជាជនយើងពិបាកក្នុងការធ្វើដំណើរទៅភោជនីដ្ឋាន យើងបានផ្តល់ភាពងាយស្រួលដល់ប្រជាជនយើង»។

លោក តុង ស៊ីវអាន បន្តឲ្យដឹងថា លោកបង្កើត ហ្វូតអែបនេះឡើង តាំងពីឆ្នាំ២០១៨មក ដែលដំបូងឡើយមានអ្នកប្រើប្រាស់ហ្វូតអែបនេះតិចតួច ប៉ុន្តែមួយរយៈចុងក្រោយនេះឃើញថា មានការកើនឡើងនូវចំនួនអ្នកប្រើប្រាស់ហ្វូតអែបនេះកាន់តែខ្លាំងឡើង ជាងអ្វីដែលលោកបានរំពឹងទុក។

ស្ថាបនិក ហ្វូតអែប បន្តទៀតថា ហ្វូតអែបបានសហការណ៍ជាមួយហាងអាហារ និងភេសជ្ជៈជិត៥០០ហាង ក្នុងរយៈពេលជិត៨ខែនេះ និងបន្តធ្វើការសហការណ៍ជាមួយហាងអាហារដទៃទៀតនៅក្នុងទីក្រុងភ្នំពេញ ដើម្បីឲ្យអតិថិជន និងអ្នកប្រើបាស្រ់ហ្វូតអែបមានជម្រើសច្រើន ទាំងមុខម្ហូប និងភេសជ្ជៈដែលគាត់ចូលចិត្ត។

លោក តុង ស៊ីវអាន៖ «ចំនួនអ្នកដែលប្រើបាស្រ់អែបរបស់ក្រុមហ៊ុនយើងខ្ញុំ គឺមានចំនួនជាង ៥០០០នាក់ ចំណែកហាងនៅក្នុងដៃជាក់ស្តែងយើងមានចំនួនជាង៣៥០ហាង និងមានចំនួនជាង ១៥០ហាងទៀតដែលយើងកំពុងតែអាប់ឡូតចូលទៅក្នុងប្រព័ន្ធ (System) របស់យើង»។

ម្ហូបអាហារ និងភេសជ្ជៈត្រូវបានរក្សាគុណភាព ជូនចំពោះអតិថិជនជាមួយនឹងទូភ្ជាប់ម៉ូតូ។ ចំណែកតម្លៃដឹកជញ្ជូនវិញ គឺនៅក្នុងក្រុងភ្នំពេញ ១ដុល្លារអាមេរិក និងនៅជាយក្រុង ២ដុល្លារអាមេរិក។ រយៈពេលនៃការដឹកជញ្ជូនអាហារជូនចំពោះអតិថិជន គឺប្រើរយៈពេល ពី៣០ទៅ៤៥នាទី។

ក្នុងមួយថ្ងៃក្រុមហ៊ុន ខាងលើទទួលបានការបញ្ជាទិញ ប្រហែលជាង៥០០។ ក្នុងនោះព្រឹកចាប់ពីម៉ោង ៧ដល់៩ព្រឹក ពេលថ្ងៃចាប់ពីម៉ោង ១១ ដល់ម៉ោង១រសៀល និងពេលល្ងាចគឺចាប់ពីម៉ោង៣ដល់ម៉ោង៧យប់។

លោក ស៊ីវ វ៉ាន់ ជាបុគ្គលិកក្រុមហ៊ុនក្នុងរាជធានីភ្នំពេញ បាននិយាយថា៖ «ចំពោះយុវវ័យបច្ចុប្បន្ននិយមប្រើទូរសព្ទអូសចុះឡើង បើគាត់មិនមកហាងដោយផ្ទាល់គឺលោកបញ្ជាទិញតាម អែប វាធ្វើឲ្យមានទំនើបកម្មមួយសម្រាប់សេវាកម្ម ជាងនេះតម្លៃគឺ (ហាង) ខ្ញុំឲ្យពី៤០ទៅ៥០ភាគរយទៅលើការបញ្ជាទិញបែបថ្មីនេះ»។

របាយការណ៍ថ្មីមួយចេញដោយ TNS ជាក្រុមហ៊ុនស្រាវជ្រាវទីផ្សារពិភពលោកបានកំណត់កត្តាជំរុញ ៥ រួមគ្នាសម្រាប់ការផ្លាស់ប្តូរគួរឲ្យចាប់អារម្មណ៍ក្នុងឥរិយាបថអ្នកប្រើប្រាស់ ដែលជំរុញឲ្យសេដ្ឋកិច្ចចិនស្ទុះងើបខ្លាំង និងស្នើឲ្យសេដ្ឋកិច្ចអាស៊ានផ្សេងទៀតគួរធ្វើដំណើរផ្លូវដូចគ្នានេះ។ កត្តាជំរុញទាំង៥នោះរួមមាន៖ ជម្រើសក្នុងការទូរទាត់ប្រាក់នៅពេលទទួលទំនិញ កម្លាំងពលកម្មទាបសម្រាប់ការចែកចាយ វត្តមានទូរសព្ទស្មាតហ្វូន និងហេដ្ឋារចនាសម្ព័ន្ធទិន្នន័យចល័ត ដែលកំពុងកើនឡើង ចំនួនប្រជាជនកើតឡើង និងសក្តានុពលផលិតភាពអាស៊ីក្នុងទីផ្សារក្នុងស្រុកប្រចាំថ្ងៃដែលអតិថិជនដើរទិញអីវ៉ាន់ប្រចាំថ្ងៃជាជាងការដើរទិញអីវ៉ាន់ប្រចាំសប្តាហ៍។

របាយការណ៍ដែលមានចំណងជើងថា៖ «ការកើនឡើងពាណិជ្ជកម្មអនឡាញរបស់អាស៊ី» បានឲ្យដឹងថា កំណើនពាណិជ្ជកម្មអនឡាញ មានសន្ទុះយ៉ាងរហ័សដែលមិននឹកស្មានដល់របស់ប្រទេសចិន ដែលបានបង្កើតការយល់ដឹងពីលក្ខខណ្ឌចាំបាច់សម្រាប់ការបង្កើនការទិញអីវ៉ាន់តាមអនឡាញ៕




*មុខម្ហូបដែលមានក្នុងប្រព័ន្ធការបញ្ជាទិញអាហារតាមអនឡាន។ រូបភាព៖ ហ្វូតអែប*

# ស៊ីម៉ាក់បង្ហាត់ពូជឆ្កែរកសារធាតុផ្ទុះបានដោយជោគជ័យ

*ដោយ៖ ផល សុផានិត*

មជ្ឈមណ្ឌល សកម្មភាពកម្ចាត់មីនកម្ពុជា ហៅកាត់ថា ស៊ីម៉ាក់ ( CMAC ) ដែលជាស្ថាប័នរបស់ជាតិមួយមានតួនាទីយ៉ាងសំខាន់ ដើម្បីលុបបំបាត់គ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ ក្នុងគោលដៅជួយដល់សេដ្ឋកិច្ចប្រជាជន ការបង្កបង្កើនផល និងអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ថ្មីៗនេះ ស្ថាប័នមួយនេះ បានបង្កាត់ពូជសត្វសុនខជាច្រើនក្បាល បានដោយជោគជ័យ ដើម្បីជាជំនួយដល់ការរុករកសារធាតុមិនទាន់ផ្ទុះនៅក្នុងដីដែលសល់ពីសង្គ្រាម។



*ឯកឧត្តម ហេង រតនា នាយកមជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា ពិនិត្យពូជឆ្កែរកសារធាតុផ្ទុះ។ រូបភាព៖ ស៊ីម៉ាក់*

លោក ប្រាក់ សូម៉េធី ប្រធានគម្រោងកម្មវិធីសុនខរបស់ស៊ីម៉ាក់ បានមានប្រសាសន៍ថា សព្វថ្ងៃស្ថាប័នជាតិមួយនេះមានសុនខ ហិតមីន និងហិតគ្រាប់មិនទាន់ផ្ទុះចំនួន ៥១ក្បាល ក្នុងនោះ៣៣ក្បាលកំពុងប្រតិបត្តិការ នៅលើទីវាល។ ១១ក្បាល កំពុងហ្វឹកហ្វឺន និង១៨ក្បាលទៀតទើបនឹងកើត។

កូនសុនខទាំង១៨ក្បាលទាំងនេះ គឺជាសំបុកដែលស៊ីម៉ាក់ធ្វើការបង្កាត់ដោយខ្លួនឯង ក្នុងយុទ្ធសាស្ត្របន្តនិរន្តភាព នៃសុនខហិតមីន កាត់បន្ថយជំនួយសុនខពីបរទេសពិសេសពីប្រទេសន័រវេស។

លោក ប្រាក់ សូម៉េធី៖ «យើងមិនអាចពឹងពាក់តែលើជំនួយរបស់ប្រទេសគេពេកនោះទេ។ តាមពិតទៅយើងចាប់ផ្ដើមតាំងពីឆ្នាំ២០០៨ ក៏ប៉ុន្តែយើងបានផ្អាកទៅវិញដោយបញ្ហាផ្នែកហិរញ្ញវត្ថុ។ ដូច្នេះបទពិសោធនៃការបង្កាត់ពូជនេះយើងមានគ្រប់គ្រាន់តាំងពីឆ្នាំ ២០០៨មក»។

លោកប្រធានគម្រោង បន្តថាសុនខទាំង១៨ក្បាលនេះ បង្កាត់ចេញពីមេ និងបាដែលជាពូជឆ្លាតបំផុត និងកំពុងតែប្រតិបត្តិការ នៅលើទីវាលក្នុងការហិតគ្រាប់មិនទាន់ផ្ទុះ។ សុនខនេះមានសមត្ថភាពខ្ពស់ក្នុងការហិតគ្រាប់រំសេវដឹងនៅក្រោមដីបានជម្រៅកន្លះម៉ែត្រ មិនចាញ់សុនខដែលនាំមកពីក្រៅប្រទេសនោះឡើយ។ សម្រាប់លោក សូម៉េធី ការបង្កាត់ពូជសុនខនេះផ្តល់ផលចំណេញច្រើនដល់ស៊ីម៉ាក់។

លោកប្រធានគម្រោងលើកឡើងថា៖ «សម្រាប់សុនខដែលយើងទិញមកស្រាប់ៗនោះ មានតម្លៃថ្លៃ ដែលមានតម្លៃដល់រាប់ម៉ឺនដុល្លារនោះ។ បើយើងបង្កាត់ខ្លួនឯងបានវាចំណេញថវិកា ផលិតផលដែលយើងធ្វើបាននោះវាមានគុណភាពល្អ »។

សុនខអាចប្រើទៅតាមជំនាញ ត្រូវបានឆ្លងកាត់ការហ្វឹកហាត់រយៈពេល ២ឆ្នាំ។ លោក ប្រាក់ សូម៉េធី ទទួលស្គាល់ថា មិនមែនគ្រប់សុនខទាំងអស់ សុទ្ធតែអាចតម្រង់ទិសឲ្យត្រូវតាមជំនាញនោះទេ ។ ជាទូទៅសត្វសុនខនេះ ផ្តល់លទ្ធផលល្អ ចំពោះការហិតរាវរកគ្រាប់មិនទាន់ផ្ទុះ បានរហូតដល់ ៩០ភាគរយឯណោះ ហើយក៏មិនដែលមានគ្រោះថ្នាក់អ្វីកើតឡើងដែរ។

ក្រៅពីការបង្វឹកសុនខ ឲ្យចេះហិតមីននោះ ស៊ីម៉ាក់ក៏មាន ការបង្ហាត់សុនខរបស់ខ្លួន ឲ្យចេះការពារសន្តិសុខ ចេះហិតគ្រឿងញៀន បង្ក្រាបបាតុកម្ម និងប្រឆាំងអំពើភេរវកម្មជាដើម។

លោកប្រធានគម្រោងបន្តថា សុនខ និងមន្ត្រីកាន់សុនខ មានសិទ្ធិចេញទៅបំពេញបេសកកម្មទៅហិតមីន និងហិតគ្រាប់មិនទាន់ផ្ទុះបាន ត្រូវឆ្លងកាត់វគ្គសិក្សាកម្រិតខ្ពស់មួយ ដែលមានរយៈពេល១ខែ ទៅ២ខែ ដើម្បីឲ្យសុនខ និងអ្នកបញ្ជាវាធ្វើការស៊ីសង្វាក់គ្នានៅលើទីលាន។ ពួកគេអាចទទួលអាជ្ញាប័ណ្ណប្រឡងជាប់វគ្គសិក្សាកម្រិតខ្ពស់នេះបាន លុះតាត្រែពួកគេប្រឡងជាប់វគ្គសិក្សានេះបានដោយជោគជ័យ។

មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជានេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩២ ដោយអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា។

ស៊ីម៉ាក់ បានវិវត្តន៍ខ្លួនក្លាយទៅជាស្ថាប័នជាតិ ទទួលបន្ទុកក្នុងវិស័យដោះមីនតាមព្រះរាជក្រឹត្យមួយ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០០០ ដើម្បីអនុវត្តន៍ឲ្យបានជោគជ័យ លើបេសកកម្មមួយសង្គ្រោះជីវិត គាំទ្រសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា។

អង្គភាពស៊ីម៉ាក់បានបង្កើតការងារគន្លឹះជាចម្បងៗរបស់ខ្លួនរួមមានកម្មវិធីហ្វឹកហ្វឺន និងស្រាវជ្រាវលើប្រព័ន្ធបច្ចេកវិទ្យាក្នុងការបោសសម្អាតមីន និងគ្រឿងមិនទាន់ផ្ទុះ។

សព្វថ្ងៃកម្ពុជានៅមានផ្ទៃដីរងការគំរាមកំហែងពីគ្រាប់មីនប្រមាណជា២.១៨៤គម$^{2}$ ក្នុងនោះផ្ទៃដីដែលមានមីនថ្មើរជើងចំនួន៩១៩ គម$^{2}$, ផ្ទៃដីដែលមានគ្រាប់បែកចង្កោម ៧៣២គម$^{2}$ និងផ្ទៃដីដែលមានសំណល់ជាតិផ្ទុះពីសង្គ្រាមផ្សេងទៀត ៤៩៧គម$^{2}$ ដោយត្រូវការថវិកាសម្រាប់បោសសម្អាតប្រមាណ ៣៥៤លានដុល្លារអាមេរិក។ គិតត្រឹមខែឧសភា ឆ្នាំ២០១៩ កម្ពុជាបានបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមលើផ្ទៃដីចំនួន ១៨៦៩ គីឡូម៉ែត្រក្រឡា។ ហើយបើតាមគោលនយោបាយរបស់រដ្ឋាភិបាលកម្ពុជា បានកំណត់យកឆ្នាំ២០២៥ជាឆ្នាំដែលកម្ពុជាអស់ការគំរាមដោយសារមីន៕



*បុគ្គលិកកំពុងមើលថែរក្សាសុនខ។ រូបភាព៖ ស៊ីម៉ាក់*

# សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ ជ្រើសតាំង លោកឪពុក ប្រ៊ុយណូ កូសម៍ ជាអ្នកគ្រប់គ្រងភូមិភាគកំពង់ចាម

*ដោយៈ លី សុវណ្ណា*


សម្ដេចប៉ាបហ្វ្រង់ស៊ីស្កូ។ *រូបភាពៈ បរទេស*


*លោក អន់តូនីសាមី ស៊ូសៃរាជ (ឆ្វេង) និងលោកឪពុក ប្រ៊ុយណូ កូសម៍ នឹងមកបំពេញមុខងារជាអ្នកគ្រប់គ្រងព្រះសហគមន៍ភូមិភាគកំពង់ចាម។*

ក្រោយពីទទួលយកពាក្យស្នើសុំលាលែងពីមុខងាររបស់លោក អន់តូនីសាមី ស៊ូសៃរាជ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ដែលចូលជាធរមានកាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩។ សម្ដេចប៉ាបហ្វ្រង់ស៊ីស្កូ បានជ្រើសតាំង លោកបូជាចារ្យ ប្រ៊ុយណូ កូសម៍ ជាអ្នកគ្រប់គ្រង ( Apostolic Administrator "vacant sede and ad nutum Sanctae Sedis" ) ព្រះសហគមន៍ភូមិភាគកំពង់ចាម បន្តពីលោកអភិបាលអន់តូនី។

លោកបូជាចារ្យ ប្រ៊ុយណូ កូសម៍ ប្រសូតនៅថ្ងៃទី ២០ ខែធ្នូ ឆ្នាំ១៩៦២ នៅប្រទេសបារាំង។ លោកទទួលអគ្គសញ្ញា តែងតាំងជាបូជាចារ្យ នៅថ្ងៃទី ៣ ខែកក្កដា ឆ្នាំ ១៩៩៤។ លោកសិក្សានៅទេវវិទ្យាល័យ ( French Pontifical Seminary ) នៃទីក្រុងរ៉ូម ហើយលោកក៏ទទួលបានសញ្ញាប័ត្រទេវវិទ្យា ( Dogmatic Theology ) ពីសាកលវិទ្យាល័យ ( the Pontifical Gregorian university ) ផងដែរ។

លោកឪពុក ប្រ៊ុយណូ ជាសមាជិក នៃក្រុមសាសនទូតក្រៅប្រទេសនាទីក្រុងប៉ារីស MEP និងទទួលបានការចាត់ឲ្យមកបំពេញបេសកកម្ម បម្រើនៅប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ១៩៩៥ មក។ គឺពីឆ្នាំ ១៩៩៥ - ១៩៩៨ លោកសិក្សាភាសាខ្មែរនៅភ្នំពេញ និងនៅស្វាយស៊ីសូផុន ខេត្តបន្ទាយមានជ័យ។ ពីឆ្នាំ ១៩៩៨ - ២០១០ លោកជាសាស្ត្រាចារ្យ និងជានាយកទេវវិទ្យាល័យ សន្តយ៉ូហានម៉ារីយ៉ាណៃ នៅភ្នំពេញ។ លោកក៏បានបំពេញមុខងារជាតំណាងពេញសិទ្ធិរបស់លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ពីឆ្នាំ ២០០១ ដល់ឆ្នាំ ២០០៧។ ពីឆ្នាំ ២០១០ ដល់ឆ្នាំ២០១៥ លោកជាបូជាចារ្យទទួលខុសត្រូវនៅព្រះវិហារសន្តយ៉ូសែប ផ្សារតូចភ្នំពេញ ព្រមទាំងមណ្ឌលសកម្មភាពភ្នំពេញខាងជើង នៃព្រះសហគមន៍ភូមិភាគភ្នំពេញ។ ក្នុងឆ្នាំ២០១៥-២០១៦ លោកបានចូលរួមទទួលបទពិសោធន៍នៅអារាម បព្វជិត បេណេឌីកតាំងនៅប្រទេសបារាំង។ ចាប់តាំងពី ឆ្នាំ២០១៦ មកដល់ពេលនេះលោកជា ទីប្រឹក្សា នៃ ក្រុមសាសនទូតក្រៅប្រទេស នាក្រុងប៉ារីស ដោយទទួលខុសត្រូវទេវវិទ្យាល័យ និងការអប់រំប្រចាំ។

បើតាមសេចក្ដីជូនដំណឹងក្នុងទូរសាររបស់លោកអភិបាលអន់តូនី ជូនលោកបូជាចារ្យ និងបព្វជិត បព្វជិតា ក្នុងភូមិភាគកំពង់ចាម បានឲ្យដឹងថា លោក ឪពុក ប្រ៊ុយណូ នឹងមកបំពេញមុខងារនៅភូមិភាគកំពង់ចាម មួយខែបន្ទាប់ពីសេចក្ដីប្រកាសតែងតាំងនេះចូលជាធរមានគឺលោកនឹងមកនៅថ្ងៃទី២៦ ខែសីហាឆ្នាំ២០១៩។

លោកអភិបាលអន់តូនីសាមី ស៊ូសៃរាជ ដែលបានសុំលាលែងពីមុខដំណែង មានប្រសាសន៍ថា លោកមានអំណរសប្បាយស្វាគមន៍ លោកឪពុកប្រ៊ុយណូ មកបំពេញមុខងារ ជាអ្នកគ្រប់គ្រងព្រះសហគមន៍ភូមិភាគកំពង់ចាម។ ទាក់ទងនឹងការលាលែងពីមុខងារជាអភិបាលកំពង់ចាម លោកអន់តូនី បានបញ្ជាក់ថា៖ «ដោយទទួលបានការណែនាំមួយចំនួនពីក្រុងរ៉ូម ហើយខ្ញុំក៏បានសរសេរលិខិត សុំលាលែងពីមុខងារជាអភិបាលភូមិភាគកំពង់ចាម ហើយសម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ បានទទួលយក និងអនុញ្ញាតនៅថ្ងៃទី២៥ ខែកក្កដា នេះ។ លោកអភិបាលបន្តថា ទោះជាយ៉ាងណាក្ដី លោកក៏នៅបន្តបម្រើព្រះសហគមន៍ក្នុងភូមិភាគកំពង់ចាមក្នុងនាមជាបូជាចារ្យ។ «ខ្ញុំមានអំណរសប្បាយ ក្នុងការបន្តមុខងារជាបូជាចារ្យ ក្នុងភូមិភាគកំពង់ចាម»។

ចំពោះមូលហេតុនៃការសុំលាលែងពីមុខងារជាអភិបាលភូមិភាគកំពង់ចាម លោកអន់តូនី បញ្ជាក់ថា មិនមានបញ្ហាអ្វីនោះទេ។ ដោយសារ លោកបានបំពេញមុខងារជាអភិបាលព្រះសហគមន៍ភូមិភាគនេះ ចំនួន ២២ឆ្នាំកន្លងមកហើយ។ ម៉្យាងទៀត លោកមានគំរូលោកអភិបាលមុនៗ គឺលោកអភិបាល អ៊ីវ រ៉ាមូស បានសុំលាលែង ពីមុខងារជាអភិបាលមុនកាលកំណត់ចូលនិវត្តន៍។ ដូច្នេះលោកមិនបាច់ចាំរហូតដល់វ័យចូលនិវត្តន៍នោះទេ ដើម្បីឲ្យលោកបូជាចារ្យដែលបន្តមុខងារជាអភិបាលពីលោកអាចមានពេលវេលាគ្រប់គ្រាន់ក្នុងការណែនាំព្រះសហគមន៍។

លោកបូជាចារ្យ ប្រ៊ុយណូ ដែលទើបទទួលការតែងតាំងមុខងារជាអ្នកគ្រប់គ្រងព្រះសហគមន៍ភូមិភាគកំពង់ចាមមានប្រសាសន៍ប្រាប់អ្នកនាំសារថា លោកបានទទួលដំណឹងអំពីសម្ដេចប៉ាប ជ្រើសតាំងលោកឲ្យបន្តមុខងារពីលោកអន់តូនីដែលលាលែងពីតំណែងកាលពីថ្ងៃទី២ ខែកក្កដា នេះ ពីលោកអគ្គរាជទូតប៊ុរីវ៉ាទីកង់។ លោកបន្តថា៖ «ខ្ញុំឆ្ងល់! តាមពិតដំណឹងនេះជាដំណឹងល្អមែន ព្រោះជាប្រទេសដែលខ្ញុំស្គាល់ ជាភូមិភាគដែលខ្ញុំស្គាល់ ជាព្រះសហគមន៍ដែលខ្ញុំស្រលាញ់។ ពេលដឹងថាខ្ញុំមានបេសកកម្មថ្មី នឹងមុខថ្មី ខ្ញុំសប្បាយមែនទែន ព្រោះខ្ញុំបានចាកចេញពីប្រទេសកម្ពុជា ៤ឆ្នាំហើយ។

លោកឪពុកប្រ៊ុយណូ ត្រូវបានក្រុមសាសនទូតក្រៅប្រទេសនាក្រុងប៉ារីស បោះឆ្នោតជ្រើសរើសជាទីប្រឹក្សានៃក្រុមនេះ សម្រាប់អាណត្តិពីឆ្នាំ ២០១៦ ដល់ឆ្នាំ២០២២។ តែពេលនេះលោកទទួលមុខងារថ្មីពីសម្ដេចប៉ាប ឲ្យបន្តមុខងារពីលោកអន់តូនី។ លោកបានត្រៀមខ្លួនជាស្រេចដើម្បីត្រលប់មកកម្ពុជាវិញ នៅចុងខែសីហានេះ។ លោកនឹងរៀនពីលោកអន់តូនី ព្រោះក្នុងរយៈពេល២២ឆ្នាំ លោកអន់តូនីបានបម្រើព្រះសហគមន៍អស់ពីសមត្ថភាព កម្លាំងកាយចិត្ត។

លោកថា៖ «ហេតុនេះ ខ្ញុំត្រូវការរៀនពីគាត់ ដើម្បីស្គាល់ស្ថានភាពនៅកំពង់ចាម និងទទួលបទពិសោធន៍ផ្សេងៗទៀត»។

លោកឪពុកប្រ៊ុយណូ បញ្ជាក់ថា៖ «ខ្ញុំកំពុងត្រៀមខ្លួនទៅកំពង់ចាម ប្រកបដោយអំណរសប្បាយ សម្រាប់ព្រះសហគមន៍ដែលខ្ញុំស្រលាញ់ សម្រាប់បងប្អូនគ្រីស្តបរិស័ទ លោកឪពុក បងស្រី និងសម្រាប់បងប្អូនដែលមិនទាន់ស្គាល់អំពីព្រះយេស៊ូ និងអំពីព្រះគ្រីស្ទ។ ក្នុងមុខងារជាបូជាចារ្យ ជាគ្រីស្តបរិស័ទ មិនមែនតែសម្រាប់យើងផ្ទាល់គឺសម្រាប់អ្នកដទៃដែលមិនទាន់ស្គាល់ព្រះយេស៊ូ»។

លោកថា ការបំពេញបេសកកម្មនេះ លោកមិនមែនម្នាក់ឯងនោះទេ គឺនៅជាមួយបងប្អូនគ្រីស្តបរិស័ទ។ យើងនឹងសហការគ្នា ដើម្បីផ្តល់សក្ខីភាពអំពីជំនឿរបស់យើង។ «ខ្ញុំជឿថា របៀបរស់នៅរបស់យើង នឹងជាសញ្ញាសំគាល់សម្រាប់គ្រីស្តបរិស័ទ និងសម្រាប់អ្នកមិនទាន់ស្គាល់ព្រះយេស៊ូ»៕

# សាសនទូតពីររូប ទទួលអគ្គសញ្ញាជាបូជាចារ្យនៅកម្ពុជា

*ដោយ៖ ដាលីស*

ក្បួនដង្ហែរយ៉ាងឱឡារិក ជាមួយស្គរបទទំនុកតម្កើង អបដំណើរ លោកឧបដ្ឋាកពីររូប ចូលទៅកាន់វេទិការ ដើម្បីទទួលតែងតាំងជាបូជាចារ្យនៃព្រះសហគមន៍កាតូលិក ក្រោមអធិបតីភាពលោកអភិបាលអូលីវីយេ ជ្មីតអឺស្ល៊ែរ រួមជាមួយវត្តមានរបស់ លោកអភិបាល និងបូជាចារ្យជាច្រើនអង្គ ដែលកំពុងបម្រើនៅក្នុងប្រទេសកម្ពុជា។ លោកឧបដ្ឋាកទាំងពីរគឺ លោក ប៉ូល ផម្រុផុង ស៊ីហារ៉ាត់ មកពីក្រុមសាសនទូត ថៃ និងលោកឧបដ្ឋាក យ៉ូសែប ង្វៀង ញឹក ខា មកពីក្រុមបព្វជិតសាឡេស៊ានដុនបូស្កូ។

លោក ប៉ូល ផម្រុផុង ស៊ីហារ៉ាត់ កើតនៅឆ្នាំ ១៩៨៥ នៅប្រទេសថៃភាគឥសាន្ត។ លោករៀននៅទេវវិទ្យាល័យ Lux Mundi នៅ សាម ផ្រាន ប្រទេសថៃ។ លោកចូលក្នុងក្រុម សាសនទូតថៃ ២០១៦ ដោយចាត់ឲ្យមកបំពេញបេសកកម្ម នៅប្រទេសកម្ពុជា។ លោកទទួលអគ្គសញ្ញាតែងតាំងជាឧបដ្ឋាក នៅឆ្នាំ២០១៨ ក្នុងភូមិភាគភ្នំពេញ។

ចំណែកលោក យ៉ូសែប ង្វៀង ញឹកខា កើតនៅដុងណៃ ប្រទេសវៀតណាម។ លោកចាប់អារម្មណ៍ជាមួយក្រុមសាឡេស៊ានតាមរយៈមិត្តភក្តិ លោកចូលរួមជាមួយ Ba than Community ក្នុងនាមជា Aspirant ក្នុងឆ្នាំ២០០០។ លោកថ្វាយពាក្យសច្ចាដំបូងក្នុងក្រុមបព្វជិតសាឡេស៊ានក្នុង ២០០៧។

បន្ទាប់ពីបង្ហាញបេក្ខជនទាំងពីរ ជាឧបដ្ឋាកនៅចំពោះមុខលោក អភិបាល និង ព្រះសហគមន៍។ លោកបូជាចារ្យ រ៉ូប៊ីត ពីសេ ដែលជានាយកទេវវិទ្យាល័យកម្ពុជា បានស្នើរសុំលោកអភិបាលអូលីវីយេ ដោយផ្អែកលើសក្ខីភាពរបស់គ្រីស្តបរិស័ទ បញ្ជាក់ថា បេក្ខជនទាំងពីររូបនេះពិតជាមានសម្ថភាពក្នុងការទទួលអគ្គសញ្ញាតែងតាំង ដើម្បីធ្វើជាបូជាចារ្យពិតប្រាកដមែន។

ជាមួយគ្នានេះដែរលោក បូជាចារ្យ សិរី តំណាងឲ្យក្រុមសាសនទូតថៃប្រចាំប្រទេសកម្ពុជា បានឡើងប្រកាសជាសាធារណៈ អំពីគុណសម្បត្តិរបស់បេក្ខភាព ផម្រុផុង ស៊ីហារ៉ាត់ ចាប់តាំងពីថ្ងៃដែលលោកបានស្គាល់គឺ បេក្ខជនរូបនេះតែងយកចិត្តទុកដាក់ចំពោះមិត្តភាពជាមួយព្រះយេស៊ូ ដោយបងប្រុសបានព្យាយាម ចូលរួមគ្រប់សកម្មភាពនានារបស់ព្រះសហគមន៍ អធិដ្ឋាន បម្រើកុមារ យុវជន និងឃើញថា បងប្រុសមានលក្ខណៈជាបូជាចារ្យអាចបម្រើបម្រើព្រះសហគមន៍ និងបងប្អូនឯទៀតៗបាននៅថ្ងៃអនាគត។ រីឯលោក បូជាចារ្យ រ៉ូអ៊ែល សូតូ តំណាងក្រុមសាឡេស៊ាន ដុនបូស្កូនៅកម្ពុជា ក៏បានប្រកាសអះអាងអំពីបេក្ខភាព យ៉ូសែប ង្វៀង ញឹកខា ផងដែរ។

ដោយយោងតាមអំណះអំណាង និងការស្នើសុំខាងលើ លោកអភិបាល បានប្រកាសជ្រើសរើសលោកឧបដ្ឋាកទាំងពីររូបជាបូជាចារ្យ ដោយមានការគាំទ្រពីព្រះយេស៊ូផងដែរ។

ក្នុងធម្មទេសនា លោកអភិបាល អូលីវីយេ បានអរគុណដល់ឪពុកម្តាយរបស់លោកទាំងពីរ ដែលថ្វាយកូននេះ សម្រាប់ព្រះសហគមន៍នៅកម្ពុជា។ លោកអភិបាលក៏បានមានប្រសាសន៍ទៅកាន់លោកឧបដ្ឋាកទាំងពីរ ដែលឆ្លើយ «បាទ! ខ្ញុំសុខចិត្ត» បេសកកម្មធ្វើគឺ ប្រកាសជំនឿ ធ្វើពិធីជ្រមុជទឹក ព្យាបាលដោយអគ្គសញ្ញាសម្រុះសម្រួល ប្រកាសដំណឹងល្អដោយបម្រើព្រះសហគមន៍ និងបងប្អូន។ លោកក៏បានលើកឡើងទៀតថា ទោះបីប្រទេសកម្ពុជាបានកំណត់យកព្រះពុទ្ធសាសនាជាសាសនារដ្ឋ ក៏ប៉ុន្តែនៅក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជា បានផ្តល់សេរីភាពខាងជំនឿសាសនាផងដែរ។

លោកអភិបាលក៏បានលើកទឹកចិត្តលោកទាំងពីរឲ្យមើលគំរូរបស់ព្រះយេស៊ូដោយបញ្ជាក់ថា៖ «ព្រះយេស៊ូ ដែលបានយកកំណើតជាមនុស្ស មកក្នុងពិភពលោកយើងរយៈ៣០ឆ្នាំ នៅភូមិណាសារ៉ែត។ ចំណែកលោកទាំងពីររូបនេះក៏ដូចគ្នា បានចូលមកក្នុងជីវិតព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជា ត្រូវលះបង់ចោលវប្បធម៌ផ្ទាល់ខ្លួន ជាវៀតណាម ជាថៃ គឺត្រូវយកចិត្តទុកដាក់ស្រឡាញ់ និងបម្រើបងប្អូន»។





លោកអភិបាលអូលីវីយេ ជ្មីតអឺស្ល៊ែរ បានប្រកាសជ្រើសរើសលោកឧបដ្ឋាកទាំងពីររូបជាបូជាចារ្យ។





លោកអភិបាលបន្តថា ត្រូវនិយាយទាក់ទងជាមួយសាសនានានា ដោយមិនបង្ខំគេឲ្យចូលសាសានាឡើយ ប៉ុន្តែត្រូវដឹងថាមានតែសក្ខីភាពនៃជីវិតទេដែលអាចនាំគេចូលក្នុងសេចក្តីស្រឡាញ់ និងជំនឿរបស់យើង។ មួយទៀតគឺសូមបើកចិត្តគំនិតទូលំទូលាយប្រកបដោយបរិយាបន្ន។ ទៅសួរសុខទុក្ខបងប្អូនដើម្បីបង្កើតទំនាក់ទំនង។ ព្រមទាំងរស់នៅក្នុងព្រះជាម្ចាស់ ដោយធ្វើពិធីអរព្រះគុណ និងអធិដ្ឋានជានិច្ច។

បន្ទាប់ពីធម្មទេសនាលោកអភិបាលអូលីវីយេ បានសួរដល់បេក្ខជនទាំងពីររូបឲ្យប្រកាសនៅចំពោះមុខព្រះសហគមន៍ ដើម្បីបញ្ជាក់ថាពិតជាមានបំណងទទួលមុខងារជាបូជាចារ្យ ចូលរួមនៅក្នុងក្រុមបូជាចារ្យ ជាសហការីរបស់ក្រុមអភិបាល ដើម្បីបម្រើ និងណែនាំប្រជារាស្ត្ររបស់ព្រះជាម្ចាស់ក្រោមការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធអស់មួយជីវិត។ លោកអភិបាលបន្តសួរ និងបេក្ខជនបានឆ្លើយ «បាទ! ខ្ញុំសុខចិត្ត» បំពេញមុខងារបម្រើព្រះបន្ទូល ដោយប្រកាសដំណឹងល្អ និងអប់រំជំនឿតាមព្រះសហគមន៍កាតូលិក សុខចិត្តធ្វើពិធីរំឭកព្រឹត្តិការណ៍នានា ជាពិសេសអគ្គសញ្ញាទាំងឡាយរបស់ព្រះសហគមន៍កាតូលិកដើម្បីលើកតម្កើងព្រះជាម្ចាស់ និងដើម្បីឲ្យប្រជារាស្ត្ររបស់ព្រះអង្គបានវិសុទ្ធ។ បេក្ខជនទាំងពីរប្រកាសទៀតថា សុខចិត្តជួយអង្វរព្រះជាម្ចាស់សម្រាប់ប្រជារាស្ត្រដោយខិតខំអធិដ្ឋាន និងសុខចិត្តរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូគ្រីស្ត។

ពិធីតែងតាំងធ្វើឡើងដោយលោកអភិបាលទ្រាបដៃ រួមជាមួយបូជាចារ្យទាំងអស់ម្តងម្នាក់ៗ ដើម្បីបញ្ជាក់ថាអស់លោករួបរួមជាមួយអភិបាលរបស់ខ្លួន ដើម្បីអង្វរព្រះវិញ្ញាណដ៏វិសុទ្ធ ។

លោកបូជាចារ្យថ្មី ទទួលឯកសណ្ឋានជាបូជាចារ្យ និងត្រូវបានលោកអភិបាលលាបប្រេងគ្រីស្មាលើបាតដៃ ដើម្បីឲ្យបូជាចារ្យថ្មីនេះបានវិសុទ្ធ ហើយណែនាំប្រជារាស្ត្ររបស់ព្រះអង្គឲ្យបានវិសុទ្ធ និងដើម្បីថ្វាយសក្ការបូជារបស់ព្រះអង្គ។

លោកបូជាចារ្យប៉ូល ផម្រុផុង ស៊ីហារ៉ាត់ បានមានប្រសាសន៍ថា៖ «ខ្ញុំបានធ្វើតាមគោលបំណងរបស់ខ្ញុំគឺ ជ្រើសរើសព្រះជាម្ចាស់»។ បន្ទាប់មកនឹងធ្វើតាមបង្គាប់ដោយ បម្រើព្រះសហគមន៍ភូមិភាគកំពង់ចាម។ ព្រមទាំងអនុវត្តតាមលោកអភិបាលអូលីវីយេ ដែលបានផ្តាំគឺ «សូមឲ្យខ្ញុំស្រឡាញ់បងប្អូន» ។ លោកថា ដើម្បីបម្រើ និងស្រឡាញ់បងប្អូន ត្រូវតែគិតថា «បងប្អូនគឺជាតំណាងព្រះជាម្ចាស់។ ម្យ៉ាងទៀតមុននឹងខ្ញុំមានថ្ងៃនេះខ្ញុំពិបាកណាស់ដោយសារខ្ញុំមានគ្រួសារ ប៉ុន្តែពេលជ្រើសរើសព្រះជាម្ចាស់ ខ្ញុំទុកទាំងអស់ឲ្យព្រះជាម្ចាស់ដោយជឿជាក់លើព្រះជាម្ចាស់ជាអ្នកដោះស្រាយ»។

ជាមួយគ្នានេះលោកបូជាចារ្យ យ៉ូសែប ង្វៀង ញឹកខា បានមានប្រសាសន៍ថា៖ «ដោយសារខ្ញុំស្រឡាញ់ព្រះជាម្ចាស់ទើបចង់ទៅជាអ្នកបួស ដើម្បីមានពេលវេលាគ្រប់គ្រាន់ជួយអ្នកក្រីក្រ និងយុវជនតាមផ្លូវរបស់លោកដុនបូស្កូ»។

លោកបន្តថា ពេលទៅជាអ្នកបួស នឹងជួយនៅក្នុងសាលាដុនបូស្កូ ដើម្បីជួយដល់យុវជនដែលជាកូនសិស្សមានការរស់នៅល្អ និងអ្នកក្រីក្រឲ្យមានសង្ឃឹម និងអធិដ្ឋានសូមឲ្យព្រះជាម្ចាស់ជួយឲ្យមានសុខភាពល្អ។

លោកក៏មានប្រសាសន៍ទៅកាន់យុវជនដែលមានបំណងចង់ក្លាយទៅជាបព្វជិត បព្វជិតា សូមអធិដ្ឋាន ទៅព្រះជាម្ចាស់។ លោកថា ចូលក្នុងជីវិតអ្នកបួសគឺ អធិដ្ឋានឲ្យបានច្រើន និងបម្រើអ្នកក្រីក្រ។

លោកបូជាចារ្យថ្មី ប៉ូល ផម្រុផុង ស៊ីហារ៉ាត់ ត្រូវបានចាត់ឲ្យទៅបម្រើព្រះសហគមន៍ភូមិភាគកំពង់ចាម។ រីឯលោកយ៉ូសែប ង្វៀង ញឹកខា ត្រូវបានលោក រ៉ូអ៊ែលប្រកាសឲ្យបម្រើក្រុមគ្រួសារដុនបូស្កូក្នុងភូមិភាគភ្នំពេញ។

ពិធីបុណ្យតែងតាំងប្រារព្ធ នៅព្រះវិហារសន្តយ៉ូសែប ផ្សារតូច ភ្នំពេញ ដោយមានគ្រីស្តបរិស័ទចូលរួមជាងពីរពាន់នាក់ នាព្រឹកថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៩៕

# អគារសម្ភពនៃមន្ទីរពេទ្យខេត្តកំពង់ឆ្នាំង ត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ឡើងវិញ

កាលពីព្រឹកថ្ងៃទី ១ ខែសីហា ឆ្នាំ២០១៩ លោក ឈួរ ច័ន្ទឌឿន អភិបាលខេត្តកំពង់ឆ្នាំង លោក វ្លាស់ទីមីល តេសារ ភារៈធារីនៃស្ថានទូតសាធារណៈរដ្ឋឆែក ប្រចាំប្រទេសកម្ពុជា លោកអភិបាល គីគេ ហ្វីការេដូ ប្រធានប្រឹក្សាភិបាលអង្គការការីតាសកម្ពុជា បានសម្ពោធដាក់ឲ្យប្រើប្រាស់ឡើងវិញ នូវអគារសម្ភពនៃមន្ទីរពេទ្យខេត្តកំពង់ឆ្នាំង។ អគារសម្ភពនេះត្រូវបានជួសជុល និងបំពាក់សម្ភារៈបរិក្ខារថ្មីដោយអង្គការការីតាសកម្ពុជា សហការជាមួយ អង្គការការីតាសឆែក ដែលឧបត្ថម្ភថវិការពីសាធារណៈរដ្ឋឆែក តាមរយៈទីភ្នាក់ងារ អភិវឌ្ឍឆែក ក្រោមគម្រោង ធ្វើឲ្យប្រសើរឡើងវិញ នូវគុណភាពនៃការថែទាំសុខភាពមាតា និងទារកនៅខេត្តកំពង់ឆ្នាំង។

*ដោយ៖ លី សុវណ្ណា*

តាមរបាយការណ៍របស់លោក ប្រាក់ វ៉ុន ប្រធានមន្ទីរសុខាភិបាលខេត្ត បានឲ្យដឹងថា មន្ទីរពេទ្យមានផ្ទៃក្រឡា ចំនួន ២២,៤៦៦ម៉ែត្រការ៉េ មាន ១៣អគារ។ អគារសម្ភពបានសាងសង់ពីឆ្នាំ ២០០១ ដោយសប្បុរសជន មានចំនួន ២០គ្រែ ប៉ុន្តែអាចទទួលស្ត្រីសម្រាលកូនជាមធ្យមពី ៣០ ទៅ៤០នាក់ក្នុង១ថ្ងៃៗ។ ដោយពិនិត្យឃើញពីសកម្មភាពពលរដ្ឋមកទទួលសេវាមានការកើនឡើង និងដើម្បីឈានទៅធ្វើការពង្រឹងគុណភាពក្នុងការផ្តល់សេវាឲ្យបានល្អប្រសើរ អគារនេះត្រូវបានកែលម្អ និងបំពាក់បន្ថែម។

លោកបន្តថា ដោយចាប់ផ្តើមធ្វើការសាងសង់ជួសជុលចាប់ពីថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៨ និង បញ្ចប់ជាស្ថាពរនៅថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០១៩ លើទំហំអគារ៣៨ x ២៣ ម៉ែត្រ មានចំនួន ១៧បន្ទប់ និងបន្ទប់អនាម័យចំនួន២ និងបំពាក់សម្ភារ បរិក្ខាពេទ្យចំនួន១៦មុខ រួមមាន៖ ឈឺតសម្រាលកូនចំនួន ១៣, ទូរដែកដាក់ឯកសារចំនួន២, រទេះរុញ ចំនួន៣, ទូដាក់សម្ភារអ្នកជំងឺ ចំនួន៣០, គ្រែសម្រាប់បុគ្គលិកចំនួន២ ម៉ាស៊ីនសីធីជី CTG ចំនួន២, ធុងសម្រាមបីពណ៌ចំនួន៩, ទូរដាក់ឱសថ ចំនួន២ , ម៉ាស៊ីនបោកគក់ Panasonic ចំនួន២គ្រឿង, Autoclave ខ្នាតធំ ចំនួន១ ម៉ាស៊ីនកំដៅទារកចំនួន២ អំពូលប្រភេទ LEDOT ចំនួន១, គ្រែសម្រាលកូនចំនួន២ និង កែវបូមកូន (Ventouse) ចំនួន១គ្រឿង ព្រមទាំងបានបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់មន្ត្រីសុខាភិបាលចំនួន ១៥រូប ដែលគម្រោងនេះ បានចំណាយថវិកាសរុបចំនួន ១៥០,៤០២ ដុល្លារអាមេរិក។

លោកអភិបាលគីគេ ប្រធានអង្គការការីតាសកម្ពុជា បានមានប្រសាសន៍ថា៖ «ខ្ញុំមានការសប្បាយចិត្ត ព្រោះទាំងអស់គ្នាបានធ្វើកិច្ចការដើម្បីប្រយោជន៍រួម ដែលយើងបានយកចិត្ត ទុកដាក់ចំពោះម្តាយ និងទារកឲ្យមានរបៀបប្រសើរជាងមុន។ ហើយមន្ទីរពេទ្យមានរបៀបថែរក្សាល្អជាងមុនផងដែរ។ លោកថា ខ្ញុំមានអំណរសប្បាយដោយអង្គការការីតាស់ក្នុង រយៈពេលជិត២ឆ្នាំ អង្គការការីតាសបានអនុវត្តគម្រោងបង្កើនគុណភាពសេវាថែទាំសុខភាពមាតា និងទារកនៅតាមមន្ទីរពេទ្យចំនួន ៣ក្នុងខេត្តកំពង់ឆ្នាំង ដែលគាំទ្រពីរាជរដ្ឋាភិបាល ជាពិសេសចូលរួមយ៉ាងពេញលេញពីលោកប្រធានមន្ទីរសុខាភិបាលខេត្ត ខ្ញុំសូមថ្លែងអំណរគុណ»។

លោកអភិបាលគីគេបានបន្តថា៖«ដោយសារយើង សហការគ្នានាំឲ្យមានដំណើរការទៅមុខ ហើយមន្ទីរពេទ្យមានដំណើរការល្អប្រសើរ និងកាន់តែប្រសើរថែមទៀត របៀបដែលយើងថែទាំកុមារមាតា និងទារក ឲ្យមានសុខភាពល្អត្រឹមត្រូវ។ អង្គការការីតាសកម្ពុជាជាអង្គការកាតូលិកមានរបៀបជាច្រើនក្នុងការបម្រើដល់បងប្អូនក្រីក្រជាពិសេស គឺផ្នែកសុខភាព។ សូមអរគុណដល់អាជ្ញាធរខេត្តកំពង់ឆ្នាំង ដែលបានគាំទ្រសកម្មភាពអង្គការការីតាសនាំឲ្យសកម្មភាពថែទាំងសេវាសុខភាពមានដំណាក់កាលទៅមុខល្អប្រសើរ»។




លោកអភិបាលគីគេ ក៏មានប្រសាសន៍សម្រាប់មាតាដែលចូលរួមក្នុងពិធីនេះដែរថា រដ្ឋាភិបាលឆែក អង្គការ និងអជ្ញាធរយកចិត្តទុកដាក់ចំពោះបងប្អូនក្រីក្រ ចង់ឲ្យបងប្អូនជាមាតាមានកិត្តិយស។ ក្នុងនោះលោកក៏អរគុណដល់ក្រុមគ្រូពេទ្យ ដែលខិតខំថែរក្សាបងប្អូននៅក្នុងមន្ទីរពេទ្យ ដោយសារការសហការគ្នានាំឲ្យយើងទៅមុខ។ យើងអភិវឌ្ឍប្រទេសកម្ពុជា យកចិត្តទុកដាក់ពីសុខភាព មាតាទារក ឲ្យប្រសើរ និងមានយុត្តិធម៌សម្រាប់អ្នកក្រីក្រ។

ក្នុងនាមអជ្ញាធរខេត្ត លោក ឈួរ ច័ន្ទឌឿន បានសម្តែងនូវសេចក្តីសោមនស្សរីករាយ និងមានសង្ឃឹមយ៉ាងជឿជាក់ថា តាមរយៈនៃសមិទ្ធផលដែលកកើត សម្ពោធដាក់ឲ្យប្រើប្រាស់នៅថ្ងៃនេះ លោកគ្រូពេទ្យទាំងអស់ ក៏ដូចជាគណៈគ្រប់គ្រងមន្ទីរពេទ្យ គឺនឹងបន្តខិតខំយកចិត្តទុកដាក់ថែទាំព្យាបាល ចំពោះស្ត្រី ទារក និងកុមាររបស់យើង អ្នកជំងឺរបស់យើង ក្នុងនោះរាប់ទាំងនយោបាយ គាំពារសង្គមរបស់យើងដែលអនុញ្ញាតឲ្យកម្មការិនីឆ្លងទន្លេ គឺមិនត្រូវបង់ប្រាក់។

លោកបន្តថា មន្ទីរពេទ្យនេះ គឺជាស្នូលបង្អែកសម្រាប់ទទួលការថែទាំព្យាបាល ដល់អតិថិជនទូទាំងខេត្ត ដូចនេះ គឺជាការប្រសើរដែលយើងបានគិតគូរកែលម្អ និងបំពាក់បរិក្ខារឲ្យសក្តិសម ជាកន្លែងផ្តល់សេវា បង្គ្រប់ប្រកបដោយគុណភាពជាពិសេសសម្រាប់ស្ត្រី។

អង្គការការីតាស កម្ពុជាបានអនុវត្តគម្រោងបង្កើនគុណភាពសេវាថែទាំសុខភាពមាតា និងទារកនៅតាមមន្ទីរពេទ្យចំនួន ៣ ក្នុងខេត្តកំពង់ឆ្នាំង



*លោកអភិបាលគីកេ ប្រធានអង្គការការីតាសកម្ពុជាកំពុងសួរសុខទុក្ខស្ត្រីជាមាតា និងកូនតូចដែលទើបសម្រាលក្នុងអគារសម្ភពនៃមន្ទីរពេទ្យខេត្តកំពង់ឆ្នាំង។*



*បុគ្គលិកមន្ទីរពេទ្យត្រូវបានទទួលការបណ្តុះបណ្តាលបន្ថែម។*

# សិក្ខាសាលាស្ដីពីការអប់រំ អំពីប្រព័ន្ធផ្សព្វផ្សាយ

*ដោយៈ លី សុវណ្ណា*








កុមារនិងយុវជននៅអាស៊ីងាយរងគ្រោះដោយសារឥទ្ធិពលអវិជ្ជមាននៃប្រព័ន្ធផ្សព្វផ្សាយជាពិសេស ប្រព័ន្ធផ្សព្វផ្សាយសង្គមនាពេលបច្ចុប្បន្ន។ ការញៀនអ៊ីនធឺណែត បណ្ដាញសង្គមនានាវីដេអូហ្គេម ការប្រើប្រាស់អ៊ីនធឺណែត ការទាក់ទងគ្នាក្នុងផ្លូវខុស ការឆបោកតាម Online ឬការសម្លាប់ខ្លួន តាមការបង្ហាញរបស់វីដេអូហ្គេម នឹងបញ្ហាមួយចំនួនទៀតដែលក្រុមគ្រួសារនៅទ្វីបអាស៊ីកំពុងប្រឈមមុខ។

SIGNIS អាស៊ី បានយកចិត្តទុកដាក់ជាប្រចាំលើការអប់រំ អំពីប្រព័ន្ធផ្សព្វផ្សាយនិងលើកកម្ពស់គំនិតផ្ដួចផ្ដើមនានា ដូចជាការផលិតសម្ភារៈអប់រំអំពីប្រព័ន្ធផ្សព្វផ្សាយ និងកម្មវិធីបណ្ដុះបណ្ដាលតាមរយៈការផ្ដល់មូលនីធិលើគម្រោងនានាជារៀងរាល់ឆ្នាំ។

សម្រាប់តំបន់ SIGNIS ASIA បានរៀបចំសិក្ខាសាលាចំនួនពីរមកហើយគឺ «បណ្ដុះបណ្ដាលការអប់រំអំពីប្រព័ន្ធផ្សព្វផ្សាយសង្គម» នៅប្រទេសឥណ្ឌា សម្រាប់អ្នកសិក្សាផ្នែកប្រព័ន្ធផ្សព្វផ្សាយ។ សិក្ខាសាលា «បណ្ដុះបណ្ដាលគ្រូបង្វឹក» នៅកូឡុំបូ ប្រទេសស្រីលង្កាសម្រាប់គ្រូអប់រំអំពីផ្នែកប្រព័ន្ធផ្សព្វផ្សាយ។

នៅឆ្នាំ ២០១៧ SIGNIS ASIA បានបោះពុម្ពសៀវភៅណែនាំសម្រាប់គ្រូបណ្ដុះបណ្ដាល អំពីប្រព័ន្ធផ្សព្វផ្សាយសង្គមដែលមាន ១៦ មេរៀន។ សៀវភៅនេះ បានចែកចាយក្នុងចំណោមបណ្ដាប្រទេសសមាជិក SIGNIS ASIA សម្រាប់ជាជំនួយដល់អ្នកសម្របសម្រួលការអប់រំអំពីប្រព័ន្ធផ្សព្វផ្សាយ។ ក្នុងនោះក៏បានបង្កើតក្រុម WhatsApp សម្រាប់សមាជិកទាំងផ្លាស់ប្ដូរយោបល់គ្នាទៅវិញទៅមក លើការអប់រំអំពីប្រព័ន្ធផ្សព្វផ្សាយសង្គម។

ឆ្នាំ ២០១៦ សមាជិក SIGNIS អាស៊ីអាគ្នេយ៍ ក៏បានជួបជុំគ្នានៅទីក្រុងម៉ានីលប្រទេសហ្វីលីភីន សម្រាប់គ្រូអប់រំផ្នែកប្រព័ន្ធផ្សព្វផ្សាយ ដោយបោះពុម្ព សៀវភៅណែនាំដោយផ្អែកលើសកម្មភាពជាក់ស្ដែង។ សៀវភៅនោះមានចំណងជើងថា «Media Literacy: Looking at the Periphery» សៀវភៅណែនាំនេះមានគោលគំនិត Media Literacy និងផែនការមេរៀនមួយចំនួន។

SIGNIS Asia គឺមានគោលបំណងមួយចងក្រង ជាក្រុមគ្រូអប់រំក្នុងទ្វីបអាស៊ី ដែលមានជំនាញក្នុងការបណ្ដុះបណ្ដាលអំពីប្រព័ន្ធផ្សព្វផ្សាយ និង អំពីប្រព័ន្ធផ្សព្វផ្សាយសង្គម។

ចុងក្រោយនេះSIGNIS ASIA បានរៀបចំសិក្ខាសាលា «"ការបណ្ដុះបណ្ដាលគ្រូ» បានធ្វើឡើងនៅថ្ងៃទី ១៦-២០ ខែកក្កដា ឆ្នាំ ២០១៩ នៅមណ្ឌលសកម្មភាពភ្នំពេញនៃព្រះសហគមន៍ភូមិភាគភ្នំពេញ ដែលមានអ្នកចូលរួមចំនួន ១៦នាក់ មកពីប្រទេសឥណ្ឌូនេស៊ី មីយ៉ាន់ម៉ា ឡាវ វៀតណាមម៉ាឡេស៊ីស្រីលង្កាឥណ្ឌា បង់ក្លាដែស កូរ៉េ ម៉ាកាវ ថៃ កម្ពុជា និងប្រទេសប៉ាគីស្ថាន៕

---



គឺមន្ទីរពេទ្យបង្អែកខេត្តកំពង់ឆ្នាំង មន្ទីរពេទ្យស្រុកកំពង់ត្រឡាច និងមន្ទីរពេទ្យស្រុកបរិបូណ៌។ ដោយផ្ដល់ការបណ្ដុះបណ្ដាល ទី១ ការគ្រប់គ្រងភាពជាអ្នកដឹកនាំសម្រាប់គណៈកម្មាធិការគ្រប់គ្រងមន្ទីរពេទ្យ មានដូចជា ការបណ្ដុះបណ្ដាលផ្នែកហិរញ្ញវត្ថុមន្ទីរពេទ្យ។ ការបណ្ដុះបណ្ដាល និងការរៀបចំបណ្ដុះបណ្ដាលសម្រាប់បុគ្គលិកគ្លីនិក។ ការថែទាំសុខភាពបន្តពូជ។ ការថែទាំកុមារ។ អាហារបំប៉នសំរាប់ម្ដាយ និងស្ត្រីមានផ្ទៃពោះ ។ ការថែទាំមាតា និងកុមារ ( ការថែទាំសុខភាពមុនពេលសម្រាល កូននិងការថែទាំទារក)។ ការសម្រាលដោយសង្គ្រោះបន្ទាន់ជាមូលដ្ឋាន ( BEMONC ) និងការថែរក្សាទារក និង បំណិនសង្គ្រោះជីវិត ( LSS ) ក្នុងភាពជាដៃគូជាមួយ NMCHC។ បណ្ដុះបណ្ដាលសំរាប់បុគ្គលិកមន្ទីរពេទ្យស្ដីពីការគ្រប់គ្រងជំងឺឆ្លង និងស្តង់ដារអនាម័យ និងអនាម័យផ្សេងៗនៅតាមមន្ទីរពេទ្យ។ ទី ២. ផលិតនិងចែកចាយសម្ភារៈព័ត៌មានអប់រំ ( IEC ) ដែលបានផ្សព្វផ្សាយនៅមន្ទីរពេទ្យនីមួយៗ ស្ដីពីការថែទាំសុខភាពមាតា និងទារកដោយប្រើទីផ្សារសង្គម និងបច្ចេកវិជ្ជាថ្មៃប្រឌិតផ្សេងទៀត។ ទី៣. ជួសជុលកែលម្អអគារសម្ភពនៅក្នុងមន្ទីរពេទ្យខេត្ត។ ទី៤. កែលម្អប្រព័ន្ធគ្រប់គ្រងទឹក និងកាកសំណល់បច្ចុប្បន្ន ( វេជ្ជសាស្ត្រ និងមិនមែនវេជ្ជសាស្ត្រ)។ ៥. ជួសជុលកែបង្គន់អនាម័យនៅតាមមន្ទីរពេទ្យ។ ទី៦. កែនីតិវិធីអនាម័យ និងអនាម័យ។. ៧. យុទ្ធនាការផ្សព្វផ្សាយព័ត៌មានសុខភាព និងសុវត្ថិភាពសាធារណៈ នៅតាមមន្ទីរពេទ្យ។ ៨. ធ្វើការស្ទាបស្ទង់មតិពេញចិត្តរបស់អតិថិជន និងប្រមូលទិន្នន័យនៅមន្ទីរពេទ្យនីមួយៗ៕



# សន្ត លូវីស និងសន្តី ហ្សេលី ម៉ាតាំង

ឆ្នាំគ្រួសារ ២០១៧-២០២០
YEAR OF FAMILY 2017-2020







## ឪពុកម្ដាយរបស់សន្តីតេរេសា នៃព្រះកុមារយេស៊ូ

### កាលវិភាគ ថ្ងៃ ខែ និងទីតាំងរបស់
### អដ្ឋិធាតុសន្តី ហ្សេលី និងសន្តលូវីស ម៉ាតាំង

| | | |
|---|---|---|
| ២៦ សីហា | : | មកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ |
| ២៧ សីហា | : | នៅមណ្ឌលសកម្មភាពតាកែវ |
| ២៨ សីហា | : | នៅមណ្ឌលសកម្មភាពកំពត |
| ២៩-៣០ សីហា | : | នៅមណ្ឌលសកម្មភាពព្រះសីហនុ |
| ៣១ សីហា | : | នៅព្រះសហគមន៍អរិយក្សត្រ |
| ១ កញ្ញា | : | នៅមណ្ឌលសកម្មភាពភ្នំពេញខាងជើង (ផ្សារតូច) |
| ២ កញ្ញា | : | នៅព្រះសហគមន៍ចំប៉ា/ទួលក្រសាំង |
| ៣ កញ្ញា | : | នៅព្រះសហគមន៍ជ្រៃធំ |
| ៤-៦ កញ្ញា | : | កម្មវិធីបោះជំរុំការត្រាស់ហៅ (ភ្នំពេញថ្មី) |
| ៧-៨ កញ្ញា | : | សន្និបាតសម្រាប់ក្រុមគ្រួសារនៅ ភ្នំពេញថ្មី |
| ៩-១៣ កញ្ញា | : | នៅភូមិភាគបាត់ដំបង នឹងកំពង់ចាម |
| ១៤ កញ្ញា (ល្ងាច) | | |
| ដល់ ១៥ កញ្ញា | : | នៅព្រះសហគមន៍បឹងទំពុន |
| ១៥ កញ្ញា (ល្ងាច) | : | នៅអារ៉ាមបងស្រីសម្ងាត់ |
| ១៦ កញ្ញា | : | និវត្តន៍ទៅបារាំង |

«អដ្ឋិធាតុរបស់សន្តី ហ្សេលី និង សន្តលូវីស ម៉ាតាំងនឹងមកដល់ព្រះសហគមន៍កាតូលិកនៅកម្ពុជាពីថ្ងៃទី២៦ សីហា ដល់១៦ កញ្ញា ២០១៩» ក្នុងរយៈពេលដែលព្រះសហគមន៍នឹងទទួលអដ្ឋិធាតុរបស់សន្តទាំងពីរនៅតាមព្រះសហគមន៍ សូមបងប្អូនចូលរួមអធិដ្ឋានទាំងអស់គ្នា ទូលអង្វរព្រះជាម្ចាស់ សូមឲ្យសន្តទាំងពីរជួយយើងខ្ញុំឲ្យមានជំនឿមាំមួយផង!